# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកគ្រូតព្រាសិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

### ផ្នែកអក្សរសាស្ត្រ

ទំព័រ

យុគន្ធរធម្មប្រីជា បាប-ពិន . . អធិប្បាយសុភាសិតខ្មែរ (តាមលំដាប់អក្សរ) . . ១៦៩

ព្រះគ្រូសទ្ធាវិទូ ពាង-សុខ . . សុភាសិតបាលីប្រែជាភាសាខ្មែរ . . . . . . . ១៨២

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . ប្រវត្តិសាស្ត្រប្រទេសចិន (តមក) . . . . . . ១៨៦

### ផ្នែកសាសនា

លោកគ្រូអាចារ្យ ប៉ាង-ខាត់ . អរិយសច្ចជាពុទ្ធភាសិត (តមក) . . . . . ១៩៦

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . ឯកកាគមិលិន្ទបញ្ហា (តមកនឹងចប់) . . . ២១០

អាចារ្យ ញ៉ែម-នៅ . . . . ប្រវត្តិសង្ខេបរបស់ឧបាសក ហួត-ទិន . . . ២២២

ឆ្នាំទី ១៧ — លេខ ៤ ខែអាវរិល ១៩៤៥ — ដំឡៃជាវៈ ១ ឆ្នាំ ១៥ រៀល ។

4/5 4

## អធិប្បាយសុភាសិតខ្មែរ

(តាមលំដាប់អក្សរ)

# យុន ឧត្តមប្រិជា ហប-ពិន

បណ្ឌិតនៃពុទ្ធសាសនបណ្ឌិត្យ    នៅមន្ទីរស្តីការសេនាបតីក្រសួងធម្មការ

### ពាក្យដើម

បទពាក្យប្រាំពីរ

ប្រទេសនានានៅក្នុងលោក
តែងមានបណ្ឌិតបេះប្រាជ្ញប្រពោក    អញ្ជោគផ្គួបផ្តើមដើមគំនិត ។
ប្រមូលពាក្យពេចន៍របស់ជាតិ    ល្អ ៗ ស្អាត ៗ មកប្រឌិត
ឲ្យឈ្មោះហៅថា "សុភាសិត"    គ្រាន់ទូន្មានចិត្តជនទាំងឡាយ ។
នៅក្នុងប្រទេសរបស់ខ្លួន    ឲ្យល្អមាំមួនច្រើនសុខសាយ
ពាក្យនោះខ្លី ៗ តែអធិប្បាយ    បានឆ្ងាយទូលាយមានដម្លៃ ។
ប្រទេសខ្មែរយើងកាលពីព្រេងនាយ    ដែលសុខសប្បាយថ្កើងថ្កានក្រៃ
ក៏មានអ្នកប្រាជ្ញអាចកែវៃ    បានតែងជាពាក្យសុភាសិត ។
សម្រាប់ប្រដៅផងសព្វជាន់    ឲ្យល្អគ្រប់គ្រាន់ប្រពៃពិត
អស់យើងជាន់ក្រោយស្ដាប់ពិនិត្យ    ឮហើយគង់គិតទុកកោតក្រែង ។

សុភាសិតនោះនៅកក់កយ ដោយអ្នកនិយាយអ្នកសំដែង
ក្លាយៗពីគ្នាប្រែនកន្ទង អ្នកណាប្រើប្រែងទើបដឹងបាន ។
តែគ្មានអ្នកប្រាជ្ញអធិប្បាយទុក ឲ្យបប់គ្រប់មុខយ៉ាងចំណាន
ពោលតែខ្លីៗជាឡាក់ហាន តតាមពាក់អាចគ្នាប៉ុណ្ណោះ ។
ខ្លួនខ្ញុំស្រឡាញ់សុភាសិត ដែលប្រាជ្ញប្រឹតយ៉ាងពិរោះ
ទើបបានអធិប្បាយភាសិតនោះ ដោយគិតសង្គ្រោះយុវជន ។
មុនតែងខ្ញុំបរមភាសិត ឲ្យបានប្រែនពិតបើយគិតគន់
បរិយាយសេចក្ដីតាមស្រាលធ្ងន់ ឲ្យយុវជនងាយស្ដាប់បាន ។
ដំណើររបៀបខ្ញុំរៀបតែង មិនវែងមិនខ្លីល្មមប្រមាណ
តាមដោយយោបល់របស់ប្រាណ យល់បានត្រឹមណាថាត្រឹមនោះ ។
ខ្ញុំសូមអភ័យពីអស់លោក អ្នកចេះប្រាជ្ញព្រោះស្មោះចំពោះ
សូមលោកគន់មើលដោយអនុគ្រោះ ចំពោះខ្លួនខ្ញុំអ្នកតែងហោង ។

ថ្ងៃពុធ ១៥ កើតខែផល្គុន ព.ស. ២៤៨៧

យុន ឧត្តមប្រិជា បាប-ពិន

## អធិប្បាយសុភាសិត

### បទពាក្យប្រាំពីរ

### ១- ឆកឆកក៏ចាយ, មេម៉ាយក៏ស្រី

សុភាសិតនេះពោលបន្ទន់
គំនិតអ្នកបង់បានប្រពន្ធ ឲ្យទន់ឲ្យទៅតាមចិត្តគំនិត ។
ថាធម្មតាស្រីជាភរិយា ទុកជាមេម៉ាយក៏ល្អពិត
បើជាក្រមុំគាស់ពីចិត្ត គំនិតមិនបានក៏មិនស្រួល ។
ប្រុស ៗ កំឡោះមានកំឡាំង នៅតាំងពីគង់វ័យក្មេងស្រួលបួល
បើបានមេម៉ាយយាំងទំនួល ក៏គួរទទួលជាភរិយា ។
ដូចអ្នកត្រូវការដោយកោដន សម្រេចសេចក្តីឃ្លានវេទនា
បើបានបាយកកក៏ល្អជា ព្រោះជាកោដនដូចគ្នាដែរ ។

### ២- ការប៉ុនក្អមមិនគិត, នៅកិតឃ្នក្តរតាំបែកមាត់

សុភាសិតនេះលោកប្រិត
ឲ្យយើងស្តាប់ហើយមានគំនិត បេះគិតការងារធំទាំងឡាយ ។
ដូចពេលកំពុងធ្វើការណា មានអ្នកចរចាអធិប្បាយ
ជាពាក្យលេះលោះនាំរំសាយ ឲ្យក្លាយព្យាយាមការធំនោះ ។
មនុស្សណាដែលពោលពាក្យបរិយាយ ឲ្យគេសាយការដូច្នោះ
អ្នកប្រាជ្ញលោកហៅមនុស្សលេះលោះ មិនបេះអត្ថុគ្រោះការម៉ឺងម៉ាត់ ។

ពេលណាដែលធ្វើការប៉ុនក្តី    មិនគិតរិតខំដោយមធ្យ័ត

ទៅគិតឯស្គរកំបែកមាត់    ឲ្យភ្លាត់ពេលការមានប្រយោជន៍ៗ

## ៣- កាប់បំពង់រង់ទឹកភ្លៀង

សុភាសិតនេះប្រាជ្ញបុរាណ

ពោលជាប្រស្នាតាមលំនាន    នៃអ្នកដែលបានចម្រើនចិត្ត ៗ

ជួនចាំការងារផងតាំងឆ្ងាយ    ដែលនៅឆ្ងាយៗ មិនទាន់គិត

គ្រាន់តែនឹកបង់ក្នុងគំនិត    រីឯនៅជិតពុំទាន់ទៀង ៗ

ពុំទាន់ប្រាកដនៅក្នុងស្មាន    ទើបប្រាជ្ញបុរាណពោលសំនៀង

ថា " កាប់បំពង់រង់ទឹកភ្លៀង "    នឹងទៀងជាបានទេនៅឡើយ ៗ

## ៤- គោកគេ ៗ ស៊ីកាតែមាត់ត្រដោតខ្ជួតពោះក្របី

សុភាសិតនេះបុរាណ

លោកពោលប្រៀបធៀបបែបប្រស្នា    ក្នុងរឿងពិតាអ្នកសំដែង ៗ

អធិប្បាយការណាឲ្យគេស្តាប់    យ៉ាងល្អបំណាប់ឥតប្រុងប្រែង

តែអ្នកអធិប្បាយមិនប្រឹងប្រែង    ប្រព្រឹត្តខ្លួនឯងមិនខ្ជាប់សោះ ៗ

ឥតមានប្រយោជន៍ដល់ខ្លួនទេ    ឯគេអ្នកស្តាប់ធ្វើតាមនោះ

គេបានប្រយោជន៍ចំណែកនោះ    ពីព្រោះគេប្រឹងឥតប្រណី ៗ

បែបនេះលោកពោលថា " គោកគេ    ស៊ីកៈខាត់ត្រដោតខ្ជួតក្របី"

បានខាងអ្នកបានតែសំដី    មិនធ្វើការអ្វីខ្លួនឯងឡើយ ៗ

### ៥- កំពង់មិនដែលស្គាល់, មាត់អកដែលស្ងៀម

សុភាសិតនេះត្រង់មិនប្រស្នា
យើងក៏ធ្លាប់ដឹងធ្លាប់ឃើញថា ធម្មតាកំពង់មិនដែលស្ងាត់ ។
ដោយមានមហាជនគេទៅមក រវេកចុះឡើងផងច្រើនក្ដាត់
នេះជាសភាពធម្មតាចាត់ មិនឲ្យមានស្ងាត់គ្រប់កន្លែង ។
ហេតុនេះអ្នកប្រាជ្ញបុរាណ ប្រៀបធៀបចប់មាយ៉ាងច្បាស់លែង
ថាដូចជាមាត់យើងនេះឯង ក៏តែងតែពោលនូវកថា ។
មិនដែលស្ងៀមស្ងាត់បាត់យូរទេ បើទុកជាគេឃាត់យ៉ាងណា
ឈប់តែបន្តិចក៏ពោលថា កើតជាកថាផ្សេងទៀតឡើង ។

### ៦- កំភ្លាញស្លាប់ពីព្រោះមាត់, ខ្លែកស្លាប់ពីព្រោះអាចម៍

សុភាសិតនេះចោទណា
លោកពោលត្រង់ ១ ទឹងប្រស្នា ទាក់ទងធម្មតាការប្រព្រឹត្ត ។
ថាត្រីកំភ្លាញវែងភ្លាត់ ស្លាប់ព្រោះតែមាត់ឥតគំនិត
ឲ្យពួកនេសាទបានឃើញពិត ទើបគេរួបរឹតចាប់បានមក ។
មួយទៀតធម្មតាព្រានចាក់ផង តែងរង់ចាំមើលក្នុងទីជ្រក
កាលឃើញអាចម៍ខ្លែកទើបគេយក ផ្ទឹមកចាក់ភាយត្រង់ទីនោះ ។
ឯពួកសត្វខ្លែកអាប់ប្រាជ្ញា តែផុះត្រង់ណាមកត្រង់នោះ
វែងជាប់ផងជាបាបគ្រោះ ពីព្រោះតែជុះទុកជាផាន ។

នេះជាគតិនៃធម្មតា ដូចមនុស្សឯណាចិត្តហៅហាន
និយាយសំដីឥតប្រមាណ ទៅតាមតែបានប្រទះមាត់ ។
ពិតតែពីពោលថាប៉ុវៗ មិនគិតខុសត្រូវបេះតែផ្ដាត់
អ្នកនោះតែងបានទោសព្រោះមាត់ ដែលផ្ដាត់មិនគិតមុខក្រោយឡើយ ។

## ៧ - កំឡាំងនៅស្រមោច, ឫទ្ធិនៅខ្មោច, អំណាចនៅក្នុងក្មេង

ពាក្យនេះមិនមែនជាប្រស្នា
ជាពាក្យពោលត្រង់តាមធម្មតា បើពិចារណាគង់ឃើញពិត ។
ដូចយ៉ាងស្រមោចផងទាំងឡាយ វាមានរូបកាយតូចល្អិតៗ
តែមានកំឡាំងខ្លាំងយ៉ាងស្និទ្ធ គេបានឃើញពិតពេលវាទាំ ។
អីវ៉ាន់ណាមួយដោយសាមគ្គី ព្រួតជួយគ្នាក្ដីយ៉ាងមួនមាំ
វាអាចផញ្ជូនអាចដឹកនាំ វត្ថុធំៗលើសខ្លួនបាន ។
ឯខ្មោចបិសាចអសុរកាយ វាប្រែក្លែងក្លាយឫទ្ធិសាមាន្យ
មនុស្សយើងឃើញហើយស្ញើបវាបាន ដោយខ្មោចវាមានឫទ្ធិមួនមាំ ។
ចំណែកឯពួកក្មេងតូចៗ ដំណូចតែត្រឹមពីរបីឆ្នាំ
អស់ពួកបាសំៗ តែងថែទាំ ទម្រាំធំដូចគេឯង ។
កាលវានៅតូចនោះធ្វើខុស កំហុសដោយល្ងង់មិនគោរពក្រែង
ដល់ម្ដាយឪពុករបស់ឯង សំដែងអំណាចវាយ៉ាងណា ។

ក៏ចាស់មិនយកទោសកំហុស ដែលទៅធ្វើខុសនោះម្ដេចម្ដា
ហេតុនេះបុរាណលោកពោលថា ដូចមាតិកាពោលខាងដើម ។

៨- កុំប្រកាស៊ីផ្លែល្វា, រម្លុលកាងា, ដក្កាំគិតឈ្លួស

ពាក្យនេះអ្នកប្រាជ្ញបុរាណ
លោកពោលត្រង់ៗនឹងប្រស្នា តាមគោលធម្មតាដែលធ្លាប់ចាត់ ។
ថាសត្វកំប្រុកតែងភាក្តា ស៊ីទុំផ្លែល្វាពេញៗឆាត់
សត្វចាបតែងហើរទន់ក្ដាត់ ធម្មតាតែងតាក់ឲ្យមួលបាន ។
សត្វឈ្លួសបើផុះហើយកាលណា រមែងក្ដៅផ្សាក្ដិតពុំក្សាន្ត
នេះជាធម្មតាពុំដែលខាន អ្នកផងដឹងបានតាំងប្រុសស្រី ។
ពាក្យនេះបើពោលជាប្រស្នា បានជាអ្នកណាធ្វើខុសអ្វី
តែគេបេះតែប្រសេចក្ដី ឲ្យខុសប៉ះចៀសពីខ្លួនគេទៅ ។
ជាយគេបេះលើគេបេះទម្លាក់ ពោសានោះឲ្យធ្លាក់ទៅបិតនៅ
លើមនុស្សណាមួយដែលឆោតល្ងង់ ឲ្យទៅជាមានទោសដួសស្នួន ។
កើតមកជាមនុស្សត្រូវសង្វាហ៍ រៀនសិល្បវិជ្ជាប្រែនពួកកង
កុំឲ្យឆោតឆ្កៅខុសទំនង ប្រយ័ត្នក្រែងស្លួងទោសដូចឈ្លួស ។

៩- កុំដិលអៀនប្រៀន ប្អួសហើយមិនរៀនបណ្ដោសថាល្ងៀ

ពាក្យនេះលោកពោលខាងបព្វជិត
ឯណាដែលបួសហើយមិនគិត ពិនិត្យរៀនសូត្រសីលសិក្ខា ។

ដល់ពេលដែលមានពួកបរិស័ទ　គេមកប្រណិប័តន៍គាល់គ្រៀបគ្រា
ហើយគេសាកសួរសាកល្បា　ពេកកមានប្រាជ្ញាលោកសំដែង ។
ធម៌អាថ៌វិន័យដែលសិក្សា　ឲ្យគេកល់ឆ្លាស្ដាប់ច្បាស់ទាំង
បានលោកជាប្រិនលើសខ្លួនឯង　ក៏គិតស្ងប់ស្ងៀមគេណាស់ណា ។
ត្រឡប់បន្ទោសមកខ្លួនឯង　ថាដែនៈព្រោះខ្ញុំអប្បប្រាជ្ញា
បួសហើយក៏ដិលមិនសិក្សា　រៀនតែសិក្សាទើបបានៈខ្ញុំ ។

## ១០ កុំទុំមុនស្រគាល

សុភាសិតនេះប្រាជ្ញបុរាណ
ប្រដៅមហាជនគ្រប់គ្គប្រាណ　ឲ្យបានប្រឹងប្រែងរៀនសិក្សា ។
រៀនអ្វីត្រូវចាំកុំអៀនប្រៀន　ត្រូវរៀនឲ្យចេះស្ទាត់ណាស់ណា
បើចេះស្ទើរៗ កុំអាលថា　"ខ្លួនបានសិក្សាចេះស្ទាត់ណាស់" ។
រៀនការណាមួយត្រូវតំណក់　ឲ្យចេះហ្មត់ចត់ប្រាកដច្បាស់
បើមិនទាន់ចេះកុំអាលផ្លាស់　ក្រឡាប់ចោលមុនរកក្រោយផ្ទួនៗ
ដូចរៀនអក្សរដ.ដើមគា　ត្រូវចាំសង្កាត់ឲ្យមាំមួន
ដកចេះបប់គ្រប់សំនួន　សឹមសំគាល់ខ្លួនថាជ្រៅជ្រាល ។
បុរាណប្រដៅសិស្សតូចធំ　ថា "កុំឲ្យទុំមុនស្រគាល"
គឺបើចំណេះនៅព្រៃព្រាល　កុំអាលលះបង់កណ្ដាលការ ។

## ១១- កុំឡើងពីចុង, ត្រូវឡើងពីគល់

សុភាសិតនេះពោលណា

លោកពោលតាមគោលនៃធម្មតា អ្នកដែលឧស្សាហ៍ឡើងគ្រឿងខ្ពស់ ។
ថាត្រូវចាប់ឡើងពីគល់ទៅ មិនត្រូវឡើងពីចុងបង្អស់
បើឡើងពីចុងនឹងមានផ្ទុស ធ្លាក់ពីខ្ពស់នោះពុំខាន ។
ពាក្យនេះលោកពោលជាពាក្យប្រៀប គឺប្រៀបនឹងអ្នកដែលចង់បាន
ចំណេះវិជ្ជាទាំងប៉ុន្មាន ចំណាប់ចំណានល្អយ៉ាងឆ្នើម ។
ត្រូវរៀនឲ្យរៀងតាមលំដាប់ គឺចាប់សិក្សាពីខាងដើម
ដូចជីកដំឡូងពីគល់ដើម ទើបចេះសម្បើមដូចប្រាថ្នា ។
បើរៀនចាប់ចុងព្រហ្មគណ នាំឲ្យវិលវល់ការសិក្សា
តែងមិនសម្រេចដូចចិន្តា ទើបថា "ត្រូវឡើងពីគល់ទៅ" ។

## ១២- កុំធ្វើការតាមខ្យល់, កុំខ្វល់តាមរលក

ពាក្យថា "កុំធ្វើការតាមខ្យល់" នេះ
ជាពាក្យអ្នកប្រាជ្ញមានចំណេះ លោកចេះប្រឌិតឲ្យមានផល ។
គឺលោកប្រដៅឲ្យចេះអត់ អំណត់ចិត្តថ្លើមឲ្យក្រៃពល
បើថ្វីតាមធម៌ព្រះសុគត បានដល់ការអត់ធ្មត់សំដី ។
លើក, ដាក់, បញ្ចោរ, ប្រមាថ នាំឲ្យអ្នកស្តាប់ភាន់ស្មារតី
នៅរបៀបតាមធម៌ជាលោកិយ ដែលជនប្រុសស្រីគួរប្រយ័ត្ន ។

## ១៣ - កុំជឿនដោយខ្យល់, កុំខ្វល់ដោយស្រី

សុភាសិតលោកហាមឃាត់
កុំឲ្យផើងផោងតាមខ្យល់មាត់ នៃអ្នកដែលភ្លាត់ពោលផ្ដេសផ្ដាសៗ
ទីងឃាត់កុំឲ្យមានចិត្តខ្វល់ អំពល់ដោយស្រីដែលមិនឈ្លាស
ព្រោះធម្មតាស្រីតែងពីសពាស ពីសពាសពាក្យពេចន៍សាំសារ ៗ
នាំប្រុសតំឡៅទៅផងប្រាជ្ញ ឲ្យលុះអំណាចកាមតណ្ហា
ប្រុសច្រើនមានគ្រោះដល់អាត្មា ទើបលោកឃាត់ថា " កុំឲ្យខ្វល់ " ៗ

## ១៤ – កុំពត់ស្រឡៅ, កុំប្រដៅស្រីខូច

នេះជាបុរាណសុភាសិត
អ្នកប្រាជ្ញលោកពោលតាមគោលពិត នៃការប្រព្រឹត្តិរបស់ស្រី ៗ
ដែលលុះអំណាចកាមតណ្ហា ទប់ទៅផ្លូវណាពោះដេរស្ដី
ខ្ទួនប្រដៅយ៉ាងណាក្ដី ក៏ពត់ឲ្យស្រីត្រង់ពុំបាន ៗ
ដូចឈើស្រឡៅនៅក្នុងព្រៃ សាបរឹងស្រួយក្រៃពន់ប្រមាណ
ពត់ឲ្យខ្វេរខ្វង់ទៅពុំបាន ធ្វើបានតែគ្រៀងណាត្រង់ៗ ៗ
រឿងនេះលោកពោលប្រៀបប្រដូច បំពោះស្រីខូចចាប់ទ្រនង់
មិនពោលសាធារណ៍ទៅទាំងស្រុង ស្រីល្អក៏គង់មានច្រើនពិត ៗ
លោកពោលចំពោះតែស្រីណា ដែលកាមតណ្ហាបណ្ដាលចិត្ត
នាំកាយឲ្យខូចខុសចរិត ទើបឥតនរណាប្រដៅបាន ៗ

## ១៤ – កុំយកកទៅលអន្ទាក់

សុភាសិតនេះប្រាជ្ញប្រិក
ហាមប្រាមមិនឲ្យយើងប្រព្រឹត្ត    ការឥតប្រយោជន៍នាំកើតទុក្ខ ។
ដូចមានអ្នកម្នាក់កើតរឿងអ្វី    ដែលជាសេចក្តីនាំទល់យុគ
ហើយមានអ្នកម្នាក់នៅសុខៗ    គិតទៅស៊ុកទ្រុកនឹងគេផង ។
ចូលរួមបំណោះដែលខ្លួនចុះ    តម្រះខ្លួនមានល្អគុណ
ឥតមាននរណាគេដឹងផង    ក៏ពោលឆ្លើយជូនឲ្យគេដឹង ។
គ្រាក្រោយបើគេមានទុរ:    គេមកតវ៉ាទាក់ពឹង
ឲ្យធ្វើការងារដែលខ្លួនដឹង    ខ្លួនត្រូវតែប្រឹងខានពុំបាន ។
ទើបលោកហាមឃាត់ជាការល្អ    ថា "កុំយកករបស់ប្រាណ
ទៅលអន្ទាក់" នាំទាន    នឹងបានលំបាកឥតអំពើ ។

## ១៥ – កុំធ្វើស្រែប្រាស់, កុំសង់ផ្ទះចូលគ្នា

សុភាសិតនេះពោលត្រង់ៗ
បើយើងពិនិត្យដោយផ្ចិតផ្ចង់    ក៏គង់ឃើញជាក់ប្រាកដណាស់ ។
ដែលបានជាលោកឃាត់អំពើ    នៃការដែលធ្វើស្រែប្រាស់
ព្រោះធ្វើដែនច្រើនតែទាស់    ទំនាស់នាំកើតទុក្ខវេទនា ។
មួយទៀតការសង់ផ្ទះសម្បែង    ចូលគ្នាក៏តែងតែទាស់គ្នា
ហេតុនេះទើបលោកហាមឃាត់ថា    "កុំធ្វើចូលគ្នាឲ្យសោះឡើយ" ។

## ១៧- កុំទុកចិត្តមេឃ-ទុកចិត្តផ្កាយ[១]

ពាក្យនេះលោកពោលជាទុកចេ
ឲ្យយើងចេះប្រើប្រាជ្ញាស្អាត កុំឲ្យប្រមាទធ្វេសគំនិត ។
ហេតុណាមិនគួរកុំបីជឿ កុំទាន់ជំនឿថាជាពិត
មនុស្សណាមិនស្រួលកុំទុកចិត្ត កុំស្និទ្ធកុំស្នាលកុំអាលគប់ ។
ទោះបីមនុស្សល្អដែលជាមិត្ត ក៏កុំទុកចិត្តឲ្យស្និទ្ធស៊ប់
ប៉ុន្តែត្រូវយកជាសម្អាត សេពគប់ជាមិត្តឲ្យមាំមួន ។
ត្រូវប្រើស្មារតីជាប់ជានិច្ច ឲ្យដឹងកលកិច្ចគេស់សំនួន ។
កុំបីជឿគេដល់ក្នុងខ្លួន ដូចពាក្យនាសិតពោលខាងដើម ។

## ១៨- កុំកាច់ទុសប្រកួតដំរី, កើតក្តីកុំប្រកួត ដីដទៅក្រោម

ពាក្យនេះអ្នកប្រាជ្ញពោលឃាត់ខាំង
មិនឲ្យមនុស្សយើងប្រព្រឹត្តតាំង ប្រណាំងប្រជែងនឹងដំរី ។
ពីព្រោះដំរីជាសត្វកាច ខានចិត្តកំណាចខ្លាំងដៃតប
កូនពេលណាមួយមានដំរី កុំបីកាច់ទិសប្រកួត ។
កាលបើប្រកួតដំរីកាច អាចនឹងត្រូវឲ្យមរណា
ហេតុនេះបុរាណលោកពោលថា កុំហានតវ៉ានឹងសត្វធំ ។
ពាក្យនេះអ្នកប្រាជ្ញលោកស្រដី ថាដូចកូនក្តីជាដំណាំ ៚

---

១ ន័យខ្លះថា កុំជឿមេឃកុំជឿផ្កាយ កុំជឿកូនថាគ្មានគរភាយ កុំជឿម្តាយថាគ្មានបំណុល ។

ត្រូវកុំប្រកួតនឹងចៅក្រម　　តំណែងអ្នកធំជាប្រធាន ។
កុំរឿងក្តីក្តាំរបស់ខ្លួន　　ត្រូវស្ងួតចិត្តលោកកុំឈ្លានពាន
តែមិនត្រូវខ្លាចត្រូវតែហ៊ាន　　ពោលរឿងខ្លួនមានឲ្យច្បាស់លាស់ ។

១៩- កុំកាត់មុខដង, កុំទទឹងមុខសេះ

ព្រោះពណ៌លោកហាមឃាត់យ៉ាងតឹង
"ថាកុំឲ្យកាត់វែងមុខដង　　ចំណែកកុំទទឹងវែងមុខសេះ" ។
ពីព្រោះចំនៀមនៃថ្លៃដង　　ជាដែកយ៉ាងវែងមុតសន្ធឹក
ដែលមនុស្សអ្នកបាំងកំពុងនឹក　　រលឹកតម្រង់ទៅត្រង់ណា ។
ដាំធម្មជាតិភាគមិនបាន　　តែកាត់ខ្លួនប្រាណបង់អាត្មា
ទើបប្រាជ្ញបុរាណលោកពោលថា　　កុំកាត់កុំការមុខដង ។
មួយទៀតធម្មតាអ្នកធ្វើស្រែ　　តែងនឹកកង្វល់ចិត្តយ៉ាងវែងបុង
តែងធ្វើដោយចិត្តក្រេវក្រោធខឹង　　ទោសនឹងអ្នកមានជាសត្រូវ ។
ឯយើងជាមនុស្សមិនធ្វើស្រែ　　កុំនឹកថាខ្លួនបង់ដើរទៅ
ទទឹងមុខសេះឲ្យបើកផ្លូវ　　នេះទៅមុខជាស្លាប់អន្តរាយ ។
រឿងនេះជាពិតឥតមានទាន　　ទើបប្រាជ្ញបុរាណលោកប្រៀបប្រាយ
ដូចកូនទីងសិស្សផងទាំងឡាយ　　កុំកាត់មុខម្តាយឪពុកគ្រូ ។
នឹងប្រៀបដូចពួកមនុស្សពាលា　　ចិត្តពាលតែងប៉ងជាសត្រូវ
បំពោះបណ្ឌិតនាំអស្រូវ　　កុំទៅស្រេតគប់នឹងពាលឡើយ ។

(មានត)

## សុភាសិតបាលី ប្រែ

ក្នុងឧបាហនវគ្គវណ្ណនា

ព្រះត្រៃសុទ្ធវិទ្ធ ភាគ-៥១ ក្រុមជំនុំព្រះត្រៃបិដកប្រែនិងរៀបរៀង

សន្តុស្សេយ្យ សចេន អសន្តុដ្ឋា ច តេន យោ
តម្បហាយិតរំ លាភិ សបេ បញ្ញាធុតព្យតីតិ ៗ

ប្រែ

ជនត្រូវតែសន្តោស កុំឲ្យទោសដោយទ្រព្យមាន ឯជនដែលឈ្នានពាន ទ្រព្យខ្លួនមានមិនស្កប់ចិត្ត ៗ លះបង់កិច្ចចំណាប់ ស្រវាចាប់កិច្ចមិនពិត តែងតែភ្លោយអំពិត ក្ដៅក្ដួលចិត្តនឹកស្ដាយក្រោយ ៗ

## អសិតាភូជាតក

ក្នុងកាលដែលកន្លងទៅហើយ កាលដែលព្រះបាទព្រហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី ព្រះពោធិសត្វបានបួសជាឥសី ញុំាងអភិញ្ញានិងសមាបត្តិ ឲ្យកើតហើយនៅក្នុងប្រទេសហិមពាន្ត ៗ ក្នុងកាលនោះ ព្រះរាជាក្នុងក្រុងពារាណសី បានទតឃើញបរិវារសម្បត្តិ នៃព្រហ្មទត្តកុមារ ដែលជាបុត្ររបស់ព្រះអង្គ ហើយកើតសេចក្ដីរង្កៀស ទើបនិរទេសបុត្រចាកដែន ៗ

ព្រះរាជបុត្របានយកនាងទេវីរបស់ខ្លួនឈ្មោះអសិតាភូ ចូលទៅប្រទេសហិមពាន្តហើយសោយ ត្រី-សាច់ និងផ្លែឈើតូច-ធំ នៅក្នុង

បណ្ណសាលា ព្រះរាជបុត្រនោះបានឃើញកិន្នរីមួយ មានចិត្តប្រតិពទ្ធ គិតយកកិន្នរីនោះជាភរិយា លែងរាប់រកនាងអសិតាភូ ហើយទៅតាមដានដើរកិន្នរីនោះ ។ នាងអសិតាភូ បានឃើញព្រះរាជបុត្រដើរតាមកិន្នរីដូច្នោះក៏គិតថា "ព្រះរាជបុត្រនេះលែងអើពើនឹងអញ គិតតែដើរតាមកិន្នរី អញមានប្រយោជន៍អ្វីនឹងព្រះរាជបុត្រនេះ" គិតហើយក៏មានចិត្តសោយ បួសទៅរកពោធិសត្វ ថ្វាយបង្គំហើយអារាធនាពោធិសត្វឲ្យសំដែងកសិណបរិកម្មដល់ខ្លួន នាងរមិលមើលកសិណ ក៏បានញុំាងអភិញ្ញានឹងសមាបត្តិឲ្យកើត ថ្វាយបង្គំពោធិសត្វ ហើយមកឈរជិតទ្វារបណ្ណសាលារបស់ខ្លួន ។ ឯព្រះរាជកុមារដើរតាមកិន្នរី ព្រោះតែដើរទៅៗលែងឃើញស្នាមជើងដែលកិន្នរីនោះទៅ ក៏អស់សង្ឃឹមហើយមានមុខឈមមករកបណ្ណសាលាវិញ ។ នាងអសិតាភូបានឃើញព្រះរាជបុត្រនោះដែលកំពុងមក ក៏ហោះទៅឯអាកាស អណ្តែតត្រដែតនៅឯផ្ទៃអាកាស ដែលមានពណ៌ដូចជាពណ៌កែវមណី នាងពោលថា (បពិត្រព្រះអយ្យបុត្រ (១) ខ្ញុំម្ចាស់បានសេពគ្គសុខក្នុងឈាននេះ ព្រោះតែអា-ស្រ័យនឹងទ្រង់) ថាហើយក៏ពោលគាថាទី ១ នេះ

ត្វមេវ ធានិមកាសិ យំ កាមា ព្យគមា តយិ
សោ យំ អប្បដិសន្ធិកោ ខរា ឆិន្នំ វេណុកំ ។

---
១ ព្រះអង្គម្ចាស់ ។

ឥឡូវនេះព្រះអង្គ បានឃើញត្រង់ទម្ងន់ឯង ចិត្តខ្ញុំក៏ប្រាសលែង មានចំណង់ចំពោះទ្រង់ ចំណង់មិនកាចក ហាក់ដំណក់ទៅបាត់បង់ ដូចក្តុក កាត់ផ្ដាច់ ដោយអាវុធដាច់ស្រឡះ ។

នាងអសិតាភូបានពោលគាថាយ៉ាងនេះហើយ កាលដែលព្រះរាជ-បុត្រកំពុងទត ក៏ហោះឡើងទៅក្នុងទីដទៃ ។ ព្រះរាជបុត្រនោះក៏ខ្សឹកខ្សួលក្នុងកាលដែលនាងអសិតាភូនោះទៅហើយ ទើបបានពោលគាថាទី ២ នេះថា

អត្ថិមំ អតិលោភេន អតិលោភមទេន ច
ឯវំ ហាយតិ អត្ថម្ហា អហំវ អសិតាភុយា ។

ជនដែលចង់បានច្រើន តែងតែផ្ទុយប្រយោជន៍ខ្លួន ព្រោះលោភហួសចំនួន នឹងលោភហួសអាចបង្កើត ។ សេចក្ដីស្រវឹងថា រីអាត្មាប្រសើត ដូចអញមាកកំណើត ភ្លាត់ទិសព្រាត់ប្រពន្ធ ។

ព្រះរាជបុត្រនោះ លុះខ្សឹកខ្សួលដោយគាថាយ៉ាងនេះហើយ ក៏នៅក្នុងព្រៃតែឯង ។

លុះអំណើះអំពីព្រះវរបិតា ទើបត្រឡប់ទៅយករាជ្យវិញ ។

អសិតាភូជាតក ចប់ ។

ឈម្ពូសរវេជ្ជកាព្យ

ឱព្រះរាជបុត្រ រូបស្រស់ជាតិសុទ្ធ មិនទាន់ស្កប់ចិត្ត បានឃើញកិន្នរី ឃ្លាតខ្ចីតាមដិត លុះតាមអស់ចិត្ត ទើបត្រឡប់មក ។ រកនាង

ទេវី ជាតិជានារី បណ្ដូលពន្លក ដែលសោយចិត្ត រិះគិតទៅរក គុណ បានទើបមក ឡូតឡើយទៅវិញ ៗ

## សារណាកថា

ព្រោះហេតុនោះ បុគ្គលអ្នកមិនបង់ប្រាសឃ្លាតចាកវត្ថុ ដែលខ្លួនបានហើយ មិនត្រូវជាអ្នកបង់ឆ្ងាំហួស មិនត្រូវជាអ្នកលោភហួស ស្រវឹងជាអញ្ជាប់ប្រែស ត្រូវតែជាអ្នកស្កប់ចិត្តនឹងវត្ថុ ដែលល្មមត្រូវបាន; បើមិនដូច្នោះទេ តែនឹងតែជាអ្នកប្រាសឃ្លាតចាកវត្ថុ ដែលខ្លួនបានហើយ ដូចជាព្រហ្មទត្តកុមារ ដែលព្រាត់ប្រាសចាកនាងសេរីភាពជាទេពីរបស់ខ្លួនអោះឯង ៗ

# ប្រវត្តិសាស្ត្រប្រទេសចិន

(តមក)

## វគ្គទី ២

## ចិននឹងហ្វូន

កាលអស់បុណ្យព្រះចៅអធិរាជវ៉ុង-ទិហើយ រាជវង្សចិនក៏មិនបានតាំងនៅជាប់ឆ្នាំប៉ុន្មាន ដោយហេតុកើតចលាចលឡើងខាងក្នុងស្រុក ទើបជាហេតុបើកឱកាសឲ្យពួកហ្វូនលុកលុយចូលមកស្រុកចិនខាងជើង ប្រទេសចិនក៏កើតវឹកវរឡើងជាខ្លាំង រហូតទាល់តែបានមេទ័ពតូចម្នាក់ ឈ្មោះលៀវ-ប៉ុង រួបរួមស្រុកចិនឡើងវិញបាន ហើយបណ្ដេញពួកហ្វូនឲ្យថយខ្ចាត់ខ្ចាយអស់ទៅ ។

មុនលៀវ-ប៉ុងឡើងគ្រងរាជសម្បត្តិនោះ ត្រូវច្បាំងតស៊ូនឹងហៀង-យូ ដែលមានលក្ខណៈកាចសាហាវដូចសត្វព្រៃ ផ្ទុយគ្នានឹងលក្ខណៈរបស់លៀវ-ប៉ុង ដែលជាមនុស្សស្លូតសុភាពរាបសាជាប្រក្រតី ។ សង្គ្រាមគ្រានោះដំបូងៗ លៀវ-ប៉ុងទន់កម្លាំងជាងហៀង-យូជាច្រើន តែនៅទីបំផុតត្រឡប់ទៅជាមានជ័យជំនះ ហើយហៀង-យូក៏ស្លាប់ទៅនៅក្នុងពុទ្ធសករាជ ៣៤២ ។ លុះលៀវ-ប៉ុងមានជ័យជំនះហៀង-យូហើយ ក៏ម្ចាស់ស្រុកឡើងទៅការពារខេត្រដែនចាន់-ស៊ី ដ្បិតមានពួកហ្វូនលុកលុយឡើងមកតាមផ្លូវនោះ ចម្បាំងគ្រានោះ លៀវ-ប៉ុង ស្ទើរតែ

អស់សង្ឃឹមទៅហើយក៏ស្រាប់តែកើតគំនិតលៃបន្លាយឡើង គឺជ្រើសរើសបានស្ត្រីរូបស្រស់ម្នាក់ ក្នុងពួកប្រពន្ធចុងរបស់ខ្លួនធ្វើជាទុយឲ្យទៅមេទ័ពរបស់ពួកហួន ជាហេតុនាំឲ្យពួកហួនលើកលែងច្បាំង ហើយថយទ័ពត្រឡប់ទៅស្រុកវិញ ក្នុងពុទ្ធសករាជ ៣៤៣ ។ របៀបលើកស្រីរូបល្អទៅបំបិនឲ្យសឹកសត្រូវឲ្យឈប់រុករានទន្ទ្រានដែនដីនោះ ជាវិធីដែលចិនចូលចិត្តធ្វើណាស់ ហើយច្រើនតែបានសម្រេចរួចបំណងផង ។

តអំពីនោះមក លៀវ-ប៉ុងបានប្រកាសតាំងខ្លួនជាព្រះចៅអធិរាជនៃប្រទេសចិនចាត់ជាបឋមក្សត្ររបស់ពួកហ័ន ទុកជារាជវង្សសំខាន់ ១ ដែលបានគ្រប់គ្រងដែនដីរបស់ចិនរហូតមកបានដល់ ៤ សតវត្សរ៍ គឺតាំងពីពុទ្ធសករាជ ៣៤៤ ដល់ពុទ្ធសករាជ ៧៦៣ ក្នុងសម័យនៃរាជវង្សហ័ននេះ ចំក្រុងរបស់ចិនជាន់ដើមតាំងនៅស៊ី - អាន់ក្នុងខេត្តបេន - ស៊ីជាវេលា ២០៧ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៣៤៤ ដល់ ៥៤៩ តពីនោះផ្លាស់មកតាំងនៅឯលោ - យ៉ាំងឬឡុក - អៀនក្នុងខេត្តហូ - ណាន់ ។ ក្សត្ររាជវង្សលៀវ - ប៉ុងមួយអង្គ ទ្រង់ព្រះនាមថារូ - ទី ដែលទ្រង់បានគ្រប់គ្រងប្រទេសចិនរហូតដល់ពុទ្ធសករាជ ៤៥៦ បានពង្រីកអាណាខេត្តចុះទៅភាគត្បូង បានច្បាំងឈ្នះទុរស្គគ់ នៅទិសខាងកើតទៀតផង ។

នៅក្នុងរវាងពុទ្ធសតវត្ស ៣០០ ឆ្នាំនោះ នៅខាងខេត្តស៊ី-កៀង (ជាខេត្តសំខាន់មួយរបស់ចិនភាគខាងត្បូង) ក្នុងខេត្តក្វាង-តុង នោះមាននគរ-ណាចក្រមួយ មានអាណាខេត្រគ្របលើទឹកដីស្រុកកុងតុង ឈ្មោះថាអាណាចក្រណានយួយ ប្រជាជនជាតិយួន តែកាលដើមត្រូវត្រួតត្រង ដែនដីជាតិចិន ៗ ដល់មកពុទ្ធសតវត្ស ៤៣៤ ចិនលុកលុយវាយបញ្ចូលអាណាចក្រនេះ ទៅក្នុងមហាអាណាចក្រចិនទាំងអស់ ៗ លុះតទៅ ៣ ឆ្នាំតមក ចិនបានលើកទៅវាយយកស្រុកកេស-ឈួនបានទៀត ដែនដីដែលយើងហៅថា ប្រទេសចិននោះ លើកលែងតែយុនណានមួយចេញ សឹងបានរួមចូលទៅក្នុងការគ្រប់គ្រងរបស់មហាអាណាចក្រចិនទាំងអស់ ៗ

ក្នុងសម័យនេះ ជាសម័យដែលមានការប្រែប្រួលយ៉ាងសំខាន់មួយនៃប្រវត្តិសាស្ត្ររបស់ពួកចិនបូព៌ាប្រទេស ៗ បើគិតមើលចុះថា កាលរវាងពុទ្ធសតវត្ស ៣០១ ឆ្នាំនោះ អាណាចក្ររបស់ចិនមិនធំសំបើម ដល់ជាក្លាយទៅជាប្រទេសធំបំផុត ក្នុងកំណត់ពេលវេលា ១០០ ឆ្នាំប៉ុណ្ណោះទេ ៗ មួយវិញទៀត ព្រះបាទវូ-ទី ទ្រង់អាចពង្រីកអាណាខេត្តឲ្យរីកចេញទៅយ៉ាងសំបើម រហូតទៅដល់ពាក់កណ្តាលទ្វីបអាស៊ី គឺទ្វីបស្ទង់នោះ ជារឿងដែលគួរជើងគួរសរសើរ សេចក្តីខ្លាំងពូកែរបស់ចិនជាច្រើន ដូចមានសេចក្តីសារស័ព្ទតទៅនេះ

# រឿងអាមាត្យឆាង-កៀន

ផែនដីដែលហៅថា ពាក់កណ្ដាលទ្វីបអាស៊ីនោះ ពីដើមនៅក្នុងអំណាចពួកហ្វូន យើងបានដឹងពីខាងដើមបន្តិចហើយថា ពួកហ្វូនបានលុកលុយទន្ទ្រានផែនដីចិន ជាច្រើនលើកច្រើនគ្រាមកហើយ ទុកជាចិនទំរាំសាងកំពែងយ៉ាងធំសំបើម ខ្ពស់ជាប់គ្រាក់ឡូសទាំងជីវិតមនុស្សជាអនេកអនន្តក៏ដោយ ក៏នៅតែមិនអាចការពារភ័យអន្តរាយរបស់ពួកហ្វូនបានឡើយ ។ ព្រះបាទវូ-ទី នៃព្រះរាជពង្សហានដែលទ្រង់បានតាំងព្រះទ័យយ៉ាងមុតមាំ ក្នុងការធ្វើចម្បាំងតទល់នឹងពួកហ្វូនឲ្យជាការដាច់ស្រេច មិនដែលចាំឲ្យពួកហ្វូនលើកទ័ពចូលមក គង់តែធ្វើដូចគ្រាមុន ៗ ទៀត ទើបទ្រង់កំណត់គ្រោងការលើកទ័ពទៅបង្ក្រាបហ្វូនដល់ស្រុកទេសរបស់ពួកហ្វូនតែម្ដង តែមានហេតុទាស់ព្រោះពួកចិនមិនសូវស្គាល់ច្រកផ្លូវនិងភូមិប្រទេសច្បាស់លាស់ល្អ ទើបទ្រង់ជ្រើសរើសតាំងបញ្ជូនអា-មាត្យដែលមានសតិបញ្ញាឈ្លាសវៃយ៉ាងចំណាប់ម្នាក់ឈ្មោះឆាង-កៀន ។ បានចេញធ្វើដំណើរទៅ ក្នុងឆ្នាំពុទ្ធសករាជ ៤០៥ ដើម្បីពិនិត្យច្រកផ្លូវនិងត្រួតមើលភូមិប្រទេស ឲ្យបានស្គាល់ជាក់ច្បាស់ ។ ឆាង-កៀន បានចេញដើរផ្លូវកោះហ្វូនក្រៃដែនមុង-លិ, បៃ-កាន, កប-តារ, ទួរស្គង់ និងអាហ្វ៉ានក្នុងវេលាដែលធ្វើដំណើរទៅតាមផ្លូវនោះ ។ ឆាង-កៀន ត្រូវពួកហ្វូនចាប់ខ្នោះនៅឃុំឃាំងជាវេលាអស់ ១០ ឆ្នាំ ទើបបានលបលួច

រត់ចូលទៅក្នុងវៃត្រវែន ក្រុងសាកេសៀនដែលជាដែនដីរបស់ពួកយូអេជី ចាង - គៀនបានតាំងខ្លួនជាមិត្រយ៉ាងល្អរបស់យូអេជី ហើយបានជួយពួកយូអេជីច្បាំងនឹងពួកក្រិកនៅបាក់ត្រៀនផង នៅទីបំផុតបានត្រឡប់ចូលមកស្រុកចិនតាមស្រុកទីបេត៍ ។ បើគិតតាំងពីវេលាដែលចាង - គៀនចេញពីស្រុកចិនទៅរហូតដល់បានត្រឡប់មកវិញ ជាវេលាដល់ ៤ ឆ្នាំ ហើយបានស្គាល់ស្ទាត់ប្រាកដភូមិប្រទេស តាមតំបន់អស់នោះយ៉ាងជាក់ច្បាស់ សមដូចព្រះរាជបំណងរបស់ព្រះបាទវូ-ទី ទើបទ្រង់រៀបចំធ្វើបច្បាំងនឹងពួកហ៊ូន ឲ្យជាការដាច់ស្រេចទៅតែម្តង ។

ប្រសិនបើយើងពិនិត្យមើលរដ្ឋបុរសទាំងពីរ គឺព្រះបាទវូ - ទីនឹងអាមាត្យចាង-គៀន នឹងឃើញថា ព្រះបាទវូ-ទីមានព្រះនិស្ស័យសន្តានរឹងប៉ុនមិនចេះរសាយ ព្រោះរាជបំរើដែលបាត់ឲ្យទៅធ្វើការ ជាវេលាជាង ១០ ឆ្នាំដូចជាចាង-គៀននោះ ប្រសិនបើជាអ្នកដទៃវិញគង់លែងទុកនានឹងធ្វើបម្រាំងកងដល់អ្នកទៅទៀត តែព្រះបាទវូ-ទីទ្រង់តាំងព្រះទ័យមុតមាំណាស់ ទើបទ្រង់ធ្វើការបានសម្រេច ។

ឯអាមាត្យចាង - គៀន គួរបាត់ជាមន្ត្រីសុចរិតស្មោះត្រង់បំផុត ចំ-ពោះព្រះមហាក្សត្ររបស់ខ្លួន ហើយថែមទាំងមានបញ្ញាឈ្លាសវៃ មានសេចក្តីក្លាហាននឹងព្យាយាមមាំណាស់ ព្រោះចាង - គៀនបានត្រួតត្រាមើលភូមិប្រទេសយ៉ាងហ្មត់ចត់ ល្បួចរៀនយុទ្ធវិធីនិងរបៀបបាត់ទ័ពរបស់

ពួកហ្លួនសម្រាប់យកទៅកបង្ហាត់បង្រៀនទាហានចិន ហេតុនេះ បានជា ក្នុងឆ្នាំពុទ្ធសករាជ ៤២៤ កងទ័ព ២ កងមានចំនួនពលទាំងសែនលើក ចេញទៅពីស្រុកចិន ដោយមានមេទ័ពពូកែ ២ ពីរនាក់ឈ្មោះហ៊ូ-កៀវ-ពិងនិងវៃ-ចុងជាអ្នកនាំទ័ព បានច្បាំងរុកលុកលុយបំផ្លាញជីវិតជាតិហ្លួន ជាច្រើនពាន់ហើយក៏វាយយកបានដែនទូវស្គង់ផង ។ គ្រប់ ១ តំបន់ដែល កងទ័ពលើកចូលទៅតែងតែមានជ័យជំនះគ្រប់អន្លើ ក្រៅពីទូវស្គង់ កងទ័ពរបស់ព្រះបាទវូ-ទីបានរុកឡើងទៅទិសឦសាន ក៏យកបានដែន លៀវ-តុងនិងដែនកៅ-លី កាលពីពុទ្ធសករាជ ៤៣៤ ដោយហេតុនេះគួរ យល់ថា ព្រះបាទវូ-ទី ក្នុងរាជ្យវង្សហាន់នេះ គួរបានទទួលកិត្តិយសថា ជាអ្នកបណ្តាលឲ្យអាណាខេត្តរីកទូលាយចេញទៅយ៉ាងសំបើម ។

លុះព្រះបាទវូ-ទីសោយព្រះទិវង្គតទៅ សេចក្តីចំរើនរុងរឿងរបស់ ចិនក៏ថយទោរទ្រាយតិចទៅ ក្នុងឆ្នាំពុទ្ធសករាជ ៤៩៣ ។ ឯលី-ក្វង-លី ជាមេទ័ពពូកែបំផុតរបស់ចិនមួយ ប្រែត្រឡប់ជាបរាជ័យចាញ់ពួកហ្លួន ទៅវិញ តាំងពីនោះមកចិនក៏ឈប់ផ្សាយអំណាចពង្រីកអាណាខេត្តរហូត មកដល់សម័យព្រះបាទស៊ុ-ក្វន-ទី ដែលទ្រង់បានគ្រប់គ្រងប្រទេស ចិនជាវេលា ២៥ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៤៧០ ដល់ ៤៩៤ ចិនត្រឡប់ មានកំឡាំងខ្លាំងពូកែឡើងវិញ មានមេទ័ពចិនពូកែម្នាក់ឈ្មោះពាន់-ហួយបានធ្វើការប្រាបប្រាមពួកហ្លួនបានសម្រេច ។ គ្រានោះ បណ្តា

ប្រទេសទាំងឡាយ នៅទ្វីបអាស៊ីកណ្ដាល សឹងធ្លាក់ទៅនៅក្នុងអំណាច របស់ព្រះចៅកាផិកផងនៃប្រទេសចិន តាំងពីកាលណោះរហូតមក ដល់ពួកកិក-ម៉េងមានអំណាច ។

ព្រះមហាក្សត្រព្រះរាជវង្សហាននេះ ទ្រង់ទំនុកបំរុងកំលាំងទាហានយ៉ាងមាំមាត់ ព្រមទាំងចាត់ការត្រួតត្រាស្រុកទេសឲ្យមានរបៀបរៀបរយល្អឡើងជាច្រើន ទ្រង់បានធ្វើទីក្រុងឲ្យជាទីប្រជុំក្រុមត្រានៃត្រៃក្រៅទូទៅ ព្រះបាទវូ-ទី ទ្រង់មានស្រុកធំៗ ជាចំណុះព្រះអង្គ ១០០ ស្រុក ។ ពីដើមមកអ្នកដែលមានដំណែងត្រួតត្រាស្រុកបាននោះ លុះតែជាមនុស្សកើតក្នុងត្រកូលជាន់ខ្ពស់ ឯព្រះបាទវូ-ទីជាមហាក្សត្រដំបូង ដែលទ្រង់ប្រកាសលើកលែងលទ្ធិទំនៀមនេះ ហើយទ្រង់ជ្រើសរើសយកមនុស្សគ្រប់ជាន់គ្រប់ថ្នាក់ដែលមានចំណេះចេះដឹងក្នុងឲ្យចូលមកធ្វើរាជការ ។ ឯព្រះមហាក្សត្រជាលំដាប់តៗមក ក្នុងព្រះរាជវង្សរបស់ព្រះអង្គ សឹងព្យាយាមបន្ថយអំណាចរបស់ពួកមល្ល៍ក្សត្រ ត្រាតែស្រុកផ្សេងៗ ក្នុងអាណាចក្រចិនមកឡើងផ្ទាល់ព្រះអង្គទាំងអស់ ព្រះបាទស៊ុ-អួន-ទី ទ្រង់ឲ្យកាត់កពួកត្រកូលជាន់ខ្ពស់ជាច្រើននាក់ ដែលអ្នកខ្ទង់រឹងទទឹងនឹងព្រះរាជអាជ្ញា ។

## វ៉ាំង-ម៉ុងឡើងគ្រងរាជ្យ

របៀបរាជការដែលរៀបរាប់មកនេះ ជាហេតុនាំឲ្យពួកត្រកូលជាន់ខ្ពស់ស្អប់ខ្ពើមរាជវង្សហានជាច្រើន ដល់មកក្នុងពុទ្ធសករាជ ៥៥២ សេនា-

បតីដែលមានចិត្តរំលោភម្នាក់ឈ្មោះ រ៉ុង-ម៉ុង បានស្ដួលព្រះមហាក្សត្រកជវង្សហ័នចេញពីរាជបល្ល័ង្ក ហើយតាំងខ្លួនឯងជាព្រះរាជាធិរាជឡើងនៃរ៉ុង-ម៉ុងថ្មីនោះ បណ្ដាលឲ្យកើតចលាចលក្នុងស្រុកឡើងយ៉ាងសំបើម ។ មានមនុស្សមួយពួកហៅថា "ពួកចិញ្ចើមក្រហម" បង្ករចលាចលឡើងក្នុងស្រុកចាន់-ទុង (ឬ-សន់-ទុង) ព្រះរាជាធិរាជដែលទើបនឹងរាជ្យថ្មី មិនអាចបង្ក្រាបឲ្យស្ងប់ស្ងាត់បាន ហើយពួកវង្សចាស់ត្រឡប់មានកំឡាំងឡើងវិញ មានព្រះអង្គម្ចាស់ក្នុងកជវង្សហ័នមួយអង្គ ព្រះនាម "លៀវ-សៀវ" ជាប្រមុខ ទើបជាហេតុឲ្យកើតចម្បាំងកាំងដល់យ៉ាងសំបើម នៅទីបំផុតក្សត្រកជវង្សចាស់មានជ័យជំនះ ហើយចាប់រ៉ុង-ម៉ុងទៅឃុំឃាំងក្នុងស្រុកស៊ី-អាំង កាលពីពុទ្ធសករាជ ៨៦៦ ដូច្នេះ ទើបឃើញថា កជវង្សចាស់ដែលទើបនឹងសាបសូន្យទៅ ១ គ្រាវេលា ១៨ ឆ្នាំនោះ ក៏ត្រឡប់តាំងឡើងជាថ្មីវិញបាន ហើយព្រះអង្គម្ចាស់លៀវ-សៀវ ក៏បានឡើងគ្រងរាជ្យជាព្រះរាជាធិរាជទ្រង់ព្រះនាម ព្រះបាទក្វាង-វូទី កាលពីពុទ្ធសករាជ ៨៦៤ ហើយទ្រង់គប់គ្រងប្រទេសចិន រហូតដល់ពុទ្ធសករាជ ៦០០ ។

## ពួកហ្វូនបែកសាមគ្គី

លុះព្រះមហាក្សត្រកជវង្សហ័ន ត្រឡប់តាំងឡើងវិញបានហើយ ទើបទ្រង់ចាប់ផ្ដើមរៀបរយការណ៍របស់ប្រទេសជាថ្មីឡើងវិញ ទ្រង់ផ្លាស់ទីក្រុង

ពីស្រុកស៊ី-អាំនទៅនៅលោយ៉ុង ដើម្បីជាប្រយោជន៍ក្នុងការត្រួតត្រាទុំក្រៃដែនបានដោយងាយផង ជាទីការពារក្រុងតាមផ្លូវយុទ្ធសាស្ត្រផង ហើយទ្រង់ចាត់ការប្រាបប្រាមពួកចិញ្ចើមក្រហមឲ្យស្ងប់កបបាប រួចស្តេចចេញទៅប្រាបប្រាមស្រុកឯទៀត ៗ នៅទីបំផុតរាយបានស្រុកសេ-ឆ្នួន ក្នុងពុទ្ធសករាជ ៥៧៩ ។ ក្រៅពីនេះ ព្រះបាទក្វាងវូ-ទីបែរទៅប្រាបប្រាមភាណាទេក្ដុជិតតាន ដែលធ្លាប់ជាចំណុះចិនអំពីដើម ទើបតែមករឹងទទឹងមិនព្រមចំណុះក្នុងខណៈដែលស្រុកចិនកំពុងកើតចលាចល ។

មានមេទ័ពចិនពូកែម្នាក់ឈ្មោះ ម៉ា-យួន រាយបានស្រុកតុងកឹងនិងកោះហៃ-ណាំ (ហៃឡាំ) កាលពីពុទ្ធសករាជ ៥៨៥ ។ គ្រានេះចិនមានជោគល្អឡើងច្រើន គឺពួកហ្វូនដែលជាសត្រូវចាស់របស់ចិន ដោយធម្មជាតិនោះ ក៏កើតបែកសាមគ្គីគ្នាជាពីរពួក គឺពួកហ្វូនទិសខាងកើតនៅចំណែកខាងស្រុកម៉ុងហ្គោលីមួយពួក ពួកហ្វូនទិសខាងលិច ចំណែកខាងស្រុកអ៊ុលតៃ ១ ពួក ។ គ្រានេះចិនកើតគំនិតឡែបខាយឡើង គឺគ្រាន់តែចាំការពារកំផែងមិនឲ្យពួកហ្វូនទាំងពីរពួកទៅមករកគ្នាបាន ទើបចាត់តាំងឋានទ័ពរក្សាទីសំខាន់ៗ ទុកដូចជាកូ-ប៊ី, ប៉េ-ចិលី នៅភាគខាងជើង ហើយនៅឯតាតុង, ឯឡាន-ចៀវ, ឯតួន-ហួន ទីងហាម៉ ។ មេទ័ពឈ្មោះ ម៉ាំ-យួន ជាអ្នកបញ្ជាការទ័ពនៅឡុងចៀវ បានធ្វើគំរូទុកយ៉ាងល្អ ដោយការទំនុកបំរុងភូមិប្រទេសឲ្យមានចំរើនឡើង គឺចិនយកទាហាន

ទៅតាំងទ្រើបរកស៊ីចិញ្ចឹមជីវិតក្នុងទឹកដីនោះ មានទំនងដូចជាក្រុងពេម បានរៀបចំរក្សាស្រុកចំណុះរបស់ខ្លួន ។ តាំងពីពេលនោះមក ពួកហ្វូនក៏រួបរួមគ្នាមិនដាច់អស់មួយគ្រា ។

តែទុកជាយ៉ាងណាក៏ដោយ ការត្រួតត្រាខេត្តដែនខុរីស្គង់ និងគ្រប់គ្រងពួកហ្វូននៅទិសខាងកើតនោះ មិនបានទទួលសេចក្ដីលំបាកវេទនាខ្លះដែរ ។

ខុរីស្គង់ភាគខាងកើតនោះ ក្នុងសម័យដែលចិនមានអំណាចត្រួតត្រា ជាទីមានដីជាតិល្អ មានចំនួនប្រជាជនច្រើនក្នុងវេលានោះ ហើយបានញែកបំបែកគ្នាចេញទៅជាច្រើនភាគ ដូចជា ខូ-តាន, ក័ប-តារ៍, យ៉ារកេន្ត, ហើយមានស្រុកព័រ ដែលជាស្រុកស្ដុកស្ដម្ភជាងគេ គឺស្រុកកុលជា និងស្រុកកាក៉ារ៍ ។

ស្រុកកុលជា ជាស្រុកស្ដុកស្ដម្ភហើយមានអំណាចរហូតមកក្នុងសម័យបុរាណកាល ស្រុកនេះជាស្រុកបានទទួលអារ្យធម៌របស់អឺរុបនិងឥណ្ឌាផ្សំគ្នា ភាសាដែលប្រើក្នុងស្រុកនេះហៅថា ភាសាតក្ការៀន មានទំនងប្រហែលទៅខាងភាសាអឺរុប ។ អារ្យធម៌របស់អឺរុបផ្សាយចូលមកក្នុងស្រុកនេះច្រើនជាងស្រុកឯទៀតៗ ក្នុងដែនខុរីស្គង់ទាំងអស់ ហើយស្រុកកុលជានេះឯងជាស្ពានចម្លងសម្រាប់បើកផ្លូវ ឲ្យព្រះពុទ្ធសាសនាចេញពីឥណ្ឌាមកស្រុកចិនបាន ។

(មានត)

អរិយសច្ច ជាពុទ្ធភាសិត

# លោកគ្រូព្រះអាចារ្យប៉ាង-ខាត់ ប្រែនិងរៀបរៀង

(តទៅ)

បុគ្គលទាំងឡាយនោះ តែងអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោក យំខ្សឹកខ្សួល សេចក្តីទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត ៗ បុគ្គលទាំងឡាយនោះ ដែលអភិរម្យក្នុងសង្ខារទាំងឡាយ ដែលតាក់តែងមានការតាក់តែងជាតិជាដើមថែទាំនោះៗ ហើយ ឈ្មោះថាតាក់តែងនូវសង្ខារទាំងឡាយ ជាគ្រឿងតាក់តែងដែលប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈ ជាដើមនោះៗ លុះបុគ្គលទាំងឡាយនោះ តាក់តែងសង្ខារទាំងឡាយមានជាតិជាដើមថែទាំនោះៗ ហើយ ក៏ធ្លាក់ចុះចូលទៅក្នុងទីងងឹតគឺ ជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តទៀត ។ តថាគតពោលទុកថា៖ "បុគ្គលទាំងឡាយនោះ មិនរួចស្រឡះអំពី ជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តទាំងនេះ មិនរួចអំពីទុក្ខទេ" ។

មហាវារៈ សំ-១៩-៥៦៣-១៣៤៤

## អ្នកដែលមិនដឹងអរិយសច្ច ឈ្មោះថាធ្លាក់ក្នុងរណ្តៅភ្លើងជានិច្ច

ម្នាលភិក្ខុទាំងឡាយ! បុគ្គលឯណាមួយ ជាសមណៈឬជាព្រាហ្មណ៍

មិនដឹងច្បាស់តាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" បុគ្គលទាំងឡាយនោះ តែងអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត ។ បុគ្គលទាំងឡាយនោះ ដែលអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយ ដែលតាក់តែងមានការតាក់តែងជាតិជាដើមថែមនោះៗ ហើយ ឈ្មោះថាតាក់តែងសង្ខារជាគ្រឿងតាក់តែង ដែលប្រព្រឹត្តទៅដើម្បីជាតិ ជរា ព្យាធិ មរណៈជាដើមនោះៗ លុះបុគ្គលទាំងឡាយនោះ តាក់តែងនូវសង្ខារទាំងឡាយមានជាតិជាដើមថែមនោះៗ ហើយ ក៏ក្ដៅក្រហល់ក្រហាយដោយភ្លើង ដោយជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តទៀត ។ តថាគតពោលទុកថា: "បុគ្គលទាំងឡាយនោះ មិនរួចស្រឡះអំពីជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តនុះទេ មិនរួចអំពីទុក្ខទេ" ។

មហាវារ សំ. ១៩-៥៦៣-១៧៣៣

## បុគ្គលត្រាស់ដឹងអរិយសច្ច ទុកជាគោលក្នុងចិត្តហើយ មិនរំភើបញាប់ញ័រដោយខ្យល់គឺវាទៈ[១] ដូចសសរថ្ម"

១ វាទៈ នេះសំដៅពោលដេញដោលគ្នាយកទាញឈ្នះ ដោយអាងសំដីថ្មាត់រៀងខ្លួន ។

ម្នាលភិក្ខុទាំងឡាយ! ភិក្ខុឯណាមួយដឹងតាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។ បើទុកជាមានសមណៈឬព្រាហ្មណ៍ជាអ្នកត្រូវការដោយវាទៈ ជាអ្នកស្វែងរកគូវាទៈ មកអំពីទិសខាងកើត ឬទិសខាងលិច, មកអំពីទិសខាងជើង ឬទិសខាងត្បូង ដោយប្រកាសខ្លួនថា: "ខ្ញុំនឹងលើកវាទៈ[១] របស់ភិក្ខុនោះចេញ ដូច្នេះ" ។ សេចក្ដីដែលសមណៈ ឬព្រាហ្មណ៍នោះ នឹងធ្វើភិក្ខុនោះឲ្យកំរើកឲ្យញាប់ញ័រឬឲ្យរំកើបដោយគន្លងធម៌នោះ មិនមែនជាឋានៈឡើយ ។

ម្នាលភិក្ខុទាំងឡាយ! ប្រៀបដូចសសរថ្មប្រវែង ១៦ ហត្ថ កប់ក្នុងដី ៨ ហត្ថ ផុតឡើងលើដី ៨ ហត្ថ បើទុកជាមានខ្យល់ព្យុះភ្លៀងធំខ្លាំងក្លា មកពីទិសខាងកើតឬទិសខាងលិច មកពីទិសខាងជើង ឬខាងត្បូង (យ៉ាងណាក៏ដោយ) ក៏សសរថ្មនោះមិនកំរើក មិនញាប់ញ័រ មិនរំកើបទៅបានឡើយ ។ សេចក្ដីនេះ ព្រោះហេតុអ្វី? ព្រោះសសរថ្មនោះគេកប់ជ្រៅផង ហើយមាំមួនផង ។

ឧហាភិរៈ តំ. ១៩-៥៥៥-១៧២.

---

១ ពាក្យដែលឲ្យទាល់តែភិក្ខុនោះចុះចាញ់ខ្លួន ។

## បុគ្គលប្រកបដោយអវិជ្ជា គឺបុគ្គលមិនដឹងអរិយសច្ច ៤ ប្រការ

ភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរមួយកន្លែង បានក្រាបទូលសួរពាក្យនេះ ចំពោះព្រះដ៏មានព្រះភាគថា: "បពិត្រព្រះអង្គដ៏ចំរើន! ព្រះអង្គតែងទ្រង់សំដែងថា: "អវិជ្ជា អវិជ្ជា ដូច្នេះ, តើអវិជ្ជានុ៎ះដូចម្តេច? ដោយហេតុដូចម្តេច បុគ្គលទើបឈ្មោះថាប្រកបដោយអវិជ្ជា?" ។ ម្នាលភិក្ខុ! កិរិយាមិនដឹងឯណានិមួយ គឺកិរិយាមិនដឹងក្នុងទុក្ខ កិរិយាមិនដឹងក្នុងហេតុប្រជុំកើតឡើងនៃទុក្ខ កិរិយាមិនដឹងក្នុងធម៌ជាគ្រឿងរំលត់ទុក្ខ កិរិយាមិនដឹងក្នុងសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ នេះតថាគតឲ្យឈ្មោះថា: "អវិជ្ជា"; ឯបុគ្គលប្រកបដោយអវិជ្ជានុ៎ះ គឺបុគ្គលមិនដឹងសេចក្តីពិតមានប្រមាណប៉ុណ្ណោះឯង ។ ម្នាលភិក្ខុ! ព្រោះហេតុនោះ អ្នកគប្បីធ្វើសេចក្តីព្យាយាម ដើម្បីឲ្យដឹងថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" នេះចុះ ។

មហាវ: សំ ១៩-៥៣៨-១៦៩៤

## កុំគិតរឿងលោក តែប្តូរគិតរឿងអរិយសច្ច.

ម្នាលភិក្ខុទាំងឡាយ! ក្នុងអតីតកាលមានរឿងរ៉ាវដំណាលថា:- មានបុរសម្នាក់តាំងចិត្តថា: "អាត្មាអញនឹងគិតនូវរឿងលោក (ផែនទំពផែនដី) ដូច្នេះ" ហើយដើរចេញអំពីក្រុងរាជគ្រឹះចូលទៅកាន់ស្រះបោក្ខរណីឈ្មោះ

សុមាគធា ហើយអង្គុយគិតនៅទៀបឆ្នេរស្រះនោះ ។ ម្នាលភិក្ខុទាំងឡាយ! បុរសនោះបានឃើញនូវសេនាទាហាន ប្រកបដោយអង្គ ៤ (គឺ: ពលដំរី. ពលសេះ. ពលរថ. ពលថ្មើរជើង) នៅឆ្នេរស្រះបោក្ខរណីឈ្មោះសុមាគធានោះ កំពុងយាត្រាចំពួលទៅតាមគល់ឈូក ។ លុះបុរសនោះមើលឃើញដូច្នោះហើយ ក៏មានសេចក្តីត្រិះរិះក្នុងខ្លួនឯងថា: "អាត្មាអញឈ្មោះថាឆ្កួតហើយ អាត្មាអញឈ្មោះថាខូចចិត្តហើយ របស់ឯណាដែលមិនមានក្នុងលោក អញឃើញរបស់នោះហើយ" ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ! ពេលនោះ បុរសនោះក៏ត្រឡប់ចូលទៅកាន់នគរវិញ ហើយដើរនិយាយប្រាប់ពួកមហាជនថា: "នែអ្នកទាំងឡាយ! ខ្ញុំឈ្មោះថាឆ្កួតហើយ ខ្ញុំឈ្មោះថាខូចចិត្តហើយ ព្រោះថា របស់ឯណាដែលមិនមានក្នុងលោកខ្ញុំបានឃើញរបស់នោះហើយ" ដូច្នេះ ។ អ្នកផងទាំងពួងសួរឈ្ងបទៀតថា "នែបុរសដ៏ចំរើន! ចុះអ្នកឆ្កួតដោយហេតុអ្វី អ្នកខូចចិត្តដោយហេតុអ្វី? របស់ឯណាមួយដែលមិនមានក្នុងលោក អ្នកបានឃើញរបស់នោះហើយឬ? ។ បុរសនោះ និយាយប្រាប់តាមដំណើរដែលឃើញគ្រប់ប្រការ, អ្នកទាំងពួងនិយាយគន់រំពង់ថា: "នែបុរស! មែនហើយ អ្នកឆ្កួតហើយ មែនហើយ អ្នកខូចចិត្តហើយ របស់នេះមិនមានក្នុងលោកទេ ហើយអ្នកបានឃើញរបស់នោះហើយ ៖ ម្នាលភិក្ខុទាំងឡាយ! ដោយពិតបុរសនោះបានឃើញពិតដូច្នោះមែន មិនមែនឃើញរបស់មិនពិតទេ ។

ម្នាលភិក្ខុទាំងឡាយ! រឿងក៏ធ្លាប់មានមកក្នុងកាលពីដើមហើយ កាលនោះមានសង្គ្រាមពួកទេវតានិងពួកអសុរ ដេញប្រកិតគ្នាមកហើយ ។ សង្គ្រាមនោះពួកទេវតាជាផែកឈ្នះ ពួកអសុរជាផែកចាញ់, លុះពួកអសុរចាញ់ហើយ ក៏ភ័យណាស់ចបួលគ្នាគេចចូលទៅកាន់អសុរបុរីវិញ តាមគល់នៃក្ពួកឈូក ដោយគិតបំភាន់ពួកទេវតាកុំឲ្យរកជួបខ្លួនឃើញ ។ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយចូរកុំគិតរឿងលោក ដោយន័យថា: "លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី" ។ ព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ! ព្រោះកិរិយាគិតនោះ មិនប្រកបដោយប្រយោជន៍ មិនមែនជាដើមនៃព្រហ្មចរិយៈមិនមែនប្រព្រឹត្តទៅដើម្បីនឿយណាយ, ដើម្បីប្រាសចាកកនៈ ដើម្បីសេចក្តីរលត់, ដើម្បីសេចក្តីស្ងប់ខ្ទាប់, ដើម្បីសេចក្តីដឹងច្បាស់, ដើម្បីសេចក្តីត្រាស់ដឹងនិងដើម្បីព្រះនិព្វានទេ ។

ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយគិត គប្បីគិតដូច្នេះវិញថា: "ដូច្នេះទុក្ខ ដូច្នេះគឺហេតុប្រជុំកើតឡើងនៃទុក្ខ ដូច្នេះគឺធម៌ជា

គ្រឿងរំលត់ទុក្ខ ដូច្នេះគឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" ។ ព្រោះហេតុអ្វី? ព្រោះហេតុថា កិរិយាគិតនេះប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចរិយធម៌ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយចាកទុក្ខ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរំលត់ ដើម្បីសេចក្តីស្ងប់ម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីត្រាស់ដឹង និងដើម្បីព្រះនិព្វាន ។

មហាវារៈ សំ. ១៩-៥៥៨- ១៣២៩.

## កុំនិយាយរឿងប្រណាំងប្រជែងបែកកន្ទែកគ្នា ចូរនិយាយតែសេចក្តីដែលរួចចាកទុក្ខ.

ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយកុំនិយាយវិគ្គាហិកកថា គឺពាក្យសំដីបែកកន្ទែកគ្នាថា: "អ្នកមិនចេះដឹងធម៌វិន័យនេះច្បាស់លាស់ទេ ខ្ញុំទើបចេះដឹងធម៌វិន័យនេះប្រាកដ អ្នកធ្វើដូចម្តេចនឹងចេះដឹងធម៌វិន័យនេះច្បាស់លាស់បាន អ្នកប្រតិបត្តិខុស ខ្ញុំទើបប្រតិបត្តិត្រូវ ពាក្យដែលគេគួរនិយាយមុន អ្នកទៅជានិយាយក្រោយ, ពាក្យដែលគួរគេនិយាយក្រោយ អ្នកទៅជានិយាយមុន, ពាក្យខ្ញុំទើបមានប្រយោជន៍ ពាក្យអ្នកមិនមានប្រយោជន៍ទេ, ពាក្យអ្នកដែលធ្លាប់ហាត់ចាំមកហើយ ឥឡូវប្រែប្រួលទៅអស់ហើយ ពាក្យរបស់អ្នកត្រូវខ្ញុំលើកឡើងបានហើយ, (គឺខ្ញុំសំគាល់ខុសបានហើយ) អ្នកត្រូវខ្ញុំផ្ចាញ់ផ្ចាលបានហើយ ដើម្បីឲ្យអ្នកដោះសារពាក្យខុសអព្ភោះបាលចេញ, បើពុំនោះ អ្នកល្បងស្ទួមកមើលចុះ"

ដូច្នេះ ។ អ្នកទាំងឡាយមិនគួរពោលរឿងនោះៗ ព្រោះហេតុអ្វី? ព្រោះថា កិរិយាពោលនោះៗ មិនមែនជាប្រយោជន៍ទេ មិនមែនជាខាងដើមនៃព្រហ្មចរិយធម៌ទេ មិនប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីសេចក្តីរលត់ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីត្រាស់ដឹងនឹងដើម្បីព្រះនិព្វានទេ ៗ

ម្នាលភិក្ខុទាំងឡាយ! កាលបើអ្នកទាំងឡាយនិយាយ អ្នកទាំងឡាយគប្បីនិយាយថា: "សេចក្តីទុក្ខដូច្នេះៗ ហេតុប្រជុំកើតឡើងនៃទុក្ខដូច្នេះៗ ធម៌ជាគ្រឿងរំលត់ទុក្ខដូច្នេះៗ សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះៗ ព្រោះហេតុអ្វី? ព្រោះហេតុថាកិរិយានិយាយនោះ ជាការនិយាយប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចរិយធម៌ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីសេចក្តីរលត់ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីត្រាស់ដឹងនឹងដើម្បីព្រះនិព្វាន ៗ

មហាវារៈ សំ. ១៩- ៥២៥- ១៦៦២.

## កុំនិយាយរឿងឥតប្រយោជន៍ តែចូរនិយាយរឿងរួចចាកទុក្ខ

ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរកុំនិយាយរឿងតិរច្ឆានកថាឥតប្រយោជន៍ច្រើនប្រការ ។ រឿងតិរច្ឆានកថា ដូចម្តេចខ្លះ? គឺៈ រឿង

ស្តេច រឿងចោរ រឿងមហាមាត្យ រឿងសេនា រឿងដែលគួរភ័យ រឿងចម្បាំង រឿងបាយ រឿងទឹក រឿងសំពត់ រឿងដេក រឿងផ្កាកំរង រឿងគ្រឿងក្រអូប រឿងញាតិ រឿងយាន រឿងស្រុក រឿងនិគម រឿងនគរ រឿងជនបទ រឿងស្រី រឿងប្រុស រឿងមនុស្សក្លៀវក្លា រឿងផ្លូវដើរ រឿងកំពង់ដងទឹក រឿងបុព្វប្រេត រឿងផ្សេងៗ រឿងលោក រឿងសមុទ្រ រឿងសេចក្តីរុងរឿង រឿងសេចក្តីទ្រុឌទ្រោម ទាំងអស់នេះ ។ ព្រោះហេតុអ្វី? ព្រោះថា កិរិយាពោលនោះៗ មិនប្រកបដោយប្រយោជន៍ មិនជាខាងដើមនៃព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីសេចក្តីរលត់ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីត្រាស់ដឹង និងដើម្បីព្រះនិព្វានទេ ។

ម្នាលភិក្ខុទាំងឡាយ! កាលបើអ្នកត្រូវនិយាយ គប្បីនិយាយថា: "សេចក្តីទុក្ខដូច្នេះៗ ហេតុប្រជុំកើតឡើងនៃទុក្ខដូច្នេះៗ ធម៌ជាគ្រឿងរំលត់ទុក្ខដូច្នេះៗ សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខដូច្នេះៗវិញ ព្រោះហេតុអ្វី? ព្រោះថា កិរិយានិយាយនោះៗប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចរិយធម៌ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីសេចក្តីរលត់ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីត្រាស់ដឹង និងដើម្បីព្រះនិព្វាន ។"

មហាវ៉ារ; សំ. ១៩- ៥២៦ -១៦៦៣.

បួសដើម្បីសេចក្តីស្ងប់រំងាប់ទុក្ខ ដូចអ្នកបួសវិន័យទាំងឡាយ

ម្នាលភិក្ខុទាំងឡាយ: កុលបុត្រទាំងឡាយឯណាមួយ ក្នុងអតីតកាលក្នុងយូរលង់ណាស់ហើយ ចេញអំពីផ្ទះហើយបួសក្នុងអនាគារិយវិន័យដោយត្រឹមត្រូវ, កុលបុត្រទាំងឡាយនោះ បួសហើយដើម្បីកិរិយាត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងឡាយបួន ៗ. ម្នាលភិក្ខុទាំងឡាយ! កុលបុត្រទាំងឡាយឯណាមួយ ក្នុងអនាគតកាលអស់កាលយូរលង់ នឹងចេញបួសក្នុងអនាគារិយវិន័យ ដោយត្រឹមត្រូវ កុលបុត្រទាំងឡាយនោះនឹងបួសដើម្បីកិរិយាត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងឡាយបួន ៗ ម្នាលភិក្ខុទាំងឡាយ! កុលបុត្រទាំងឡាយឯណានីមួយ បួសក្នុងបច្ចុប្បន្នកាលនេះចេញចាកផ្ទះបួសក្នុងអនាគារិយវិន័យ ដោយត្រឹមត្រូវ, កុលបុត្រទាំងឡាយនោះ បួសដើម្បីកិរិយាត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងបួន ៗ អរិយសច្ចទាំងឡាយបួននោះតើដូចម្តេច? អរិយសច្ចទាំងឡាយបួននោះគឺ: សេចក្តីពិតដ៏ប្រសើរគឺទុក្ខ ១ សេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ ១ សេចក្តីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ ១ សេចក្តីពិតដ៏ប្រសើរ គឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ១ ៗ

ម្នាលភិក្ខុទាំងឡាយ! កុលបុត្រទាំងឡាយឯណានីមួយ ក្នុងអតីតកាលក្នុងយូរលង់ណាស់ហើយ ចេញចាកផ្ទះហើយបួសក្តី នឹងបួសក្តី

(ក្នុងអនាគតកាល) ឬស (ក្នុងបច្ចុប្បន្នកាល) ក្តី ក្នុងអនាគារិយវិន័យ ដោយត្រឹមត្រូវ, កុលបុត្រទាំងឡាយនោះ សុទ្ធតែឬសដើម្បីកិរិយាត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងឡាយបួន ៗ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើសេចក្តីព្យាយាមដើម្បីឲ្យដឹងថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ" — នេះចុះ ៗ

មហាវ: សំ. ១៩ - ឬ២១ - ១: ៥៦

## បើមិនដឹងអរិយសច្ចតថាគតមិនសន្មតថា ជាសមណៈឬជា ព្រាហ្មណ៍ ក្នុងវិន័យតថាគតទេ

ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយឯណាមួយ ជាសមណៈឬជាព្រាហ្មណ៍ មិនដឹងច្បាស់តាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ" ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ! សមណៈទាំងឡាយនោះក្តី ព្រាហ្មណ៍ទាំងឡាយនោះក្តី តថាគតមិនសន្មត (មិនទទួលស្គាល់) ថាជាសមណៈក្នុងពួកសមណៈទាំងឡាយនោះទេ មិនសន្មត (មិនទទួលស្គាល់) ថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទាំងឡាយនោះទេ, ព្រោះអ្នកទាំងឡាយនោះ មិនបានធ្វើឲ្យជាក់ច្បាស់ នូវប្រយោជន៍នៃខ្លួនជាសមណៈឬជាព្រាហ្មណ៍ ដោយប្រាជ្ញាដ៏ក្រៃលែងក្នុងបច្ចុប្បន្នហើយសម្រេចនៅ ៗ

ម្នាលភិក្ខុទាំងឡាយ! រីឯបុគ្គលឯណាមួយ ជាសមណៈ ឬជាព្រាហ្មណ៍ដឹងតាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ! សមណៈទាំងឡាយនោះឯងក្ដី ព្រាហ្មណ៍ទាំងឡាយនោះឯងក្ដី ទើបតថាគតសន្មត (ទទួលស្គាល់) ថាជាសមណៈក្នុងពួកសមណៈទាំងឡាយ ថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទាំងឡាយ, ព្រោះអ្នកទាំងឡាយនោះ បានធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍នៃខ្លួនជាសមណៈឬជាព្រាហ្មណ៍ ដោយប្រាជ្ញាដ៏ក្រៃលែងក្នុងបច្ចុប្បន្នកាលនេះ ហើយសម្រេចនៅ ។

មហាវ. ទី. ២៤-៣១០-២៨៣

## បើអាកនៅហាំចង់ដឹងរឿងដែលមិនជាប្រយោជន៍ហើយ ក៏ស្លាប់ទៅហោល ដែរទេ

ម្នាលមាលុង្ក្យបុត្រ! បុគ្គលឯណានិយាយយ៉ាងនេះថា: "ខ្ញុំមិនទាន់ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគទេ ព្រោះព្រះដ៏មានព្រះភាគមិនទាន់សំដែងវិជ្ជា ១០ ប្រការដល់ខ្ញុំព្រះអង្គថា: "លោកទៀងដូច្នេះក្ដី លោកមិនទៀងដូច្នេះក្ដី លោកមានទីបំផុតដូច្នេះក្ដី លោកមិនមានទីបំផុតដូច្នេះក្ដី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្ដី ជីវិតដទៃសរីរៈក៏ដទៃដូច្នេះក្ដី សត្វស្លាប់ហើយកើតទៀតដូច្នេះក្ដី សត្វស្លាប់ហើយមិនកើតទៀត

ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មានមិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តីឬអ្វី។ ម្នាលមាលុង្ក្យបុត្រ! តថាគតសំដែងដំណើរនោះឲ្យមិនទាន់ទេ បុគ្គលនោះមុខជានឹងធ្វើមរណកាលទៅ (មុនសំដែង) ដោយពិត" ។ ម្នាលមាលុង្ក្យបុត្រ! ដូចជាបុរសត្រូវសរ (របស់សេនានៃស្តេចដទៃ) ដែលលាបប្រឡាក់ដោយថ្នាំពិសក្រាស់ មិត្រអាមាត្យញាតិសាលោហិតរបស់បុរសនោះ ក៏ចូលទៅរកពេទ្យជាអ្នកវះ ។ បុរសនោះនិយាយយ៉ាងនេះថា "ខ្ញុំមិនទាន់ឲ្យដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ជាក្សត្រឬព្រាហ្មណ៍ជាវេស្សៈឬសុទ្ទៈនៅឡើយទេ...មិនទាន់ស្គាល់នាមគោត្រ ... ខ្ពស់ទាបឬកណ្តាល ខ្មៅ សណ្តែកបាយឬប្រផេះ... ស្រុកឬនិគម ឬនគរឯណា ៗ ... មិនទាន់ស្គាល់ធ្នូដែលបុគ្គលនោះបាញ់ជាកាំភ្លើងឬស្នា ... មិនទាន់ស្គាល់ខ្សែធ្នូនោះជាសម្បកពក់ឬពន្លៃឬឫស្សីជាសរសៃសត្វឬសម្បកខ្លុងព័ណ៌ ឬល្មើកដោះ ... មិនទាន់ស្គាល់ព្រួញជាព្រួញឈើព្រៃ ឬព្រួញឈើដែលគេដាំ ទៀតដោយស្លាបសត្វក្អែកឬប្រមង់ ខ្លែង ក្ងោក ឬទុង ... រុំដោយសរសៃគោឬក្របី ឬសីហៈខ្លាឬស្វា ... មានមុខរដូល សំប៉ែតដូចកាំបិតខាងជៀង ឬមុខស្រោបដែកមានមុខដូចពន្លាក ធ្មេញត្រីទន្សងជាដើម ៗ ម្នាលមាលុង្ក្យបុត្រ! បុរស

នោះចាំដឹងដំណើរនោះមិនទាន់ទេ មុខជាបុរសនោះ ទីងភ្លើមរណកាល ពោលទៅពុំបាន ៗ ម្នាលមាលុង្ក្យបុត្រ! បុគ្គលឯណា និយាយយ៉ាងនេះថា: "ខ្ញុំមិនទាន់ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះដ៏មានព្រះភាគទេ ព្រោះព្រះដ៏មានព្រះភាគមិនទាន់សំដែងទិដ្ឋិ ១០ ប្រការ មានលោកទៀងដូច្នេះក្តីជាដើម ដល់ខ្ញុំព្រះអង្គ, ម្នាលមាលុង្ក្យបុត្រ! តថាគតនឹងសំដែងដំណើរនោះឲ្យមិនទាន់ទេ បុគ្គលនោះមុខជាភ្លើមរណកាលទៅ (មុខសំដែង) ពុំបាន មានឧបមេយ្យដូចជាបុរសដែលត្រូវសរមុតនោះឯង ៗ

ម្នាលមាលុង្ក្យបុត្រ! កាលបើមានទិដ្ឋិ ១០ ប្រការ សេចក្តីយល់ឃើញថា: "លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ហើយការអប់រំព្រហ្មចរិយធម៌ក៏មិនមាន តែជាតិក៏មាន ជរាក៏មាន ព្យាធិក៏មាន មរណៈក៏មាន សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីទុក្ខចិត្ត សេចក្តីក្រៀមក្រំចិត្ត ក៏មានជាធម៌ដែលតថាគតបញ្ញត្ត ថាជាសេចក្តីវិនាសក្នុងបច្ចុប្បន្ន ៗ

(មានត)

ឯកសារគម៌ល៌ន្តបញ្ញា

ហ្សង់និពន្ធមន្ត្រី ញ៉ុក-ថែម រួបរួមប្រែ

(តមកនឹងចប់)

## អង្គ ៥ របស់សមុទ្រ

១— មិនរួមប្រើប្រាស់បុកប្រហល់ដោយសាកសព ។

២ – ជាទីប្រជុំនៃកែវមុក្តា កែវពេទូរ្យ កែវប្រពាឡ កែវផលិក មានប្រការផ្សេង ៗ មិនឲ្យធ្លាក់ធ្លាយកក់ឃ្លាទៅក្រៅ ។

៣ – ជ្រៅជ្រាលទៅដោយមហាភូតជាច្រើន ។

៤– ពេញប្រៀបដោយទឹកថ្មី ដែលហូរចូលមកអំពីទន្លេតូច-ធំ ទាំងឡាយ និងទឹកដែលធ្លាក់ចុះមកពីក្នុងអាកាស ប៉ុន្តែមិនដែលហៀរហួសពីមាត់ច្រាំងសមុទ្រឡើយ ។

៥ – មិនបេះភ្លេតស្កប់ស្កល់ពេញប្រៀបដល់មាត់ច្រាំងដោយទឹកដែលហូរមកពីទន្លេទាំងពួងនិងទឹកដែលធ្លាក់ចុះមកពីអាកាស ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការគឺ:

១ — មិននៅរួមនឹងកិលេសជាគ្រឿងសៅហ្មង មានលោភៈ ទោសៈ មោហៈ ជាដើម ។

២ – ទ្រទ្រង់គុណនូវកែវ គឺគុណវិសេសផ្សេងៗ មានមគ្គផលនិព្វាន ជាដើម ហើយរក្សាទុកតែខាងក្នុងមិនឲ្យសាយចេញទៅខាងក្រៅ ។

៣ - នៅអាស្រ័យនឹងសព្រហ្មចារី ដែលជាកល្យាណមិត្រ ជាអ្នកទ្រទ្រង់នូវគុណធម៌មានប្រាថ្នាតិច សន្តោស មានខ្មាស មានសីលជាទីស្រឡាញ់ជាដើម ។

៤ - មិនក្លែងល្មើសសិក្ខាបទ ព្រោះហេតុតែលាភយសសរសើរ សុខក្តី ព្រោះហេតុតែការចិញ្ចឹមជីវិតក្តី ។

៥ - ទុកជាបានស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ជានិច្ច ក៏មិនបេះធ្មែតធ្មូន់សោះឡើយ ។

## អង្គ៥របស់ផែនដី:

១ - ទុកជាគេចាក់កេយកយវត្ថុ-អាក្រក់ច្រើនយ៉ាងច្រើនប្រការ គឺ កប្បូរ ពុំសែន ក្រស្នា ក្រពេះចូនច័ន្ទន៍ មានហាមជាដើមក្តី ស្លេស្ម ឈាម ខ្ទញ់ ទឹកសម្បោរ បន្ទោបង់ឧច្ចារៈបស្សាវៈជាដើមក្តី ក៏ផែនដីនៅដដែលមិនត្រេកអរ មិនអន់ចិត្តសោះឡើយ ។

២ - ប្រាសចាកការតាក់តែងដោយគ្រឿងប្រដាប់ប្រដាទាំងលាបស្រឡាបដោយគ្រឿងក្រអូបផ្សេងៗ ។

៣ - មិនមានឧបៈទ្វាះ មិនមានរន្ធ មិនមានប្រហោង មានសាច់ណែនតាន់ជាផ្ទាំងមួយ ។

៤ - ទ្រទ្រង់នូវសព្វសារពើផ្សេងៗជាដើម គឺ ភូមិ ស្រុក នគរ ជនបទ ដើមឈើ ភ្នំ ស្ទឹង ទន្លេ ព្រែក ស្រះ សត្វទ្វិបាទ ចតុប្បាទ

សត្វបក្សី និងមនុស្សប្រុស-ស្រី មិនមានសេចក្ដីខ្វល់ប្រកួសព្រួញទាន់សោះឡើយ ។

៤ — ប្រាសចាកសេចក្ដីក្រេវក្រោធអន់ចិត្ត ឥតគិតបៀតបៀនសត្វដទៃឲ្យលំបាកឡើយ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ:

១ — ទឹងខ្លួនខ្ជាប់ខ្ជួន មិនសំដែងការការខ្ទស់តាប មិនក្រេវក្រោធ មិនអន់ចិត្ត ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។

២ ប្រាសចាកការប្រដាប់តាក់តែងដោយគ្រឿងប្រដាប់ដែលមិនសមគួរដល់ភេទរបស់ខ្លួន តែងតាំងខ្លួនដោយគ្រឿងក្រអូបគឺសីល ។

៣ — មានសីលបរិសុទ្ធ មិនមានទោស មិនដាច់ធ្លុះ មិនមានប្រហោង ណែនណាន់ខ្ជាប់ខ្ជួន ។

៤ — មិនខ្វល់ប្រកួស ។ សព្វាហ៍ប្រកបករណីយកិច្ចតាំងឲ្យលួយទៀង សមទឹងមុខក្រសួងរបស់ខ្លួន ឲ្យសមទឹងភេទរបស់ខ្លួនសព្វៗ កាលទៅ ។

៥ — ផុតចាកសេចក្ដីក្រេវក្រោធខឹងអន់ចិត្ត មានចិត្តស្មើដោយផែនដី ។

## អង្គ ៥ របស់ធម្មជាតិទឹក

១ — ទឹងស្ងៀម មិនរញ្ជួយ មិនសៅហ្មង ថ្លាស្អាតជាប្រក្រតី ។

២ — មានលក្ខណៈត្រជាក់ជានិច្ច ។

៣ — ជម្រះលាងរបស់សៅគ្រោកឲ្យស្អាតបាន ។

៤— ជាទីប្រាជ្ញដ៏ក្រៃលែង នៃមនុស្សសត្វទាំងពួង ។

៥— មិនយករបស់ឥតប្រយោជន៍ចូលទៅឲ្យដល់អ្នកឯណានីមួយឡើយ គឺសម្រេចប្រយោជន៍ដល់អ្នកដទៃគ្រប់គ្នា ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការគឺ :

១— មិននិយាយកុហក មិននិយាយញុះញង់បំបែកស្រុកទេសលោក ជាអ្នកមានវាចាពីរោះល្អ បរិសុទ្ធជាប្រក្រតី ។

២— បរិបូណ៌ដោយមេត្តា ខន្តី សោរច្ចៈ អហិង្សាជាប្រក្រតី ស្វែងរកតែប្រយោជន៍ មានសេចក្ដីអនុគ្រោះដល់សព្វសត្វទាំងឡាយ ។

៣— ទុកជានៅក្នុងទីណា ៗ ក៏ដោយ ក៏គប្បីធ្វើកិច្ចដែលជាប្រយោជន៍ដល់មនុស្សគ្រប់ជាន់ ។

៤— មានប្រាជ្ញាគិត សន្ដោស គេចទៅពួនក្នុងទីស្ងាត់ ប្រតិបត្តិខ្លួនជាទីប្រាជ្ញារបស់សត្វលោកកល់គ្នាជានិច្ច ។

៥— មិនបង្កការចលាចល ឈ្លោះប្រកួតប្រកាន់វិវាទ ឬសង្គ្រាមកើតឡើង មិនធ្វើអំពើអាក្រក់ដោយកាយ វាចាចិត្តឡើយ ។

## អង្គ ៥ របស់ភ្លើង:

១— ដុតស្មៅ ឈើ ស្លឹកឈើ ចំបើង ។

២— មិនអាណិត មិនអាសូរដល់គ្រឿងដែលឆេះភ្លើងនោះឡើយ ។

៣— ជាគ្រឿងកំចាត់ងងឹតចេញបាន ។

៤- ឲ្យកើតសេចក្ដីកក់ក្ដៅហាំងនៃក្រៃលែង ។

៥- កំចាត់ងងឹតឲ្យភ្លឺឡើងបាន ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺៈ

១- ដុតកំដៅកិលេស ទាំងខាងក្នុង ទាំងខាងក្រៅដោយភ្លើងគឺញាណ ។

២- មិនមានចិត្តអាណិតអាសូរ ក្នុងកិលេសទាំងឡាយឡើយ ។

៣- ញុំាងភ្លើងជាគ្រឿងដុតបំផ្លាញ គឺវិរិយៈឲ្យកើតឡើងដើម្បីកំចាត់បង់នូវគងកិលេសទាំងពួង ។

៤- ប្រាសចាកសេចក្ដីត្រេកអរនិងអន់ចិត្ត និងបដិឃៈ រមែងមានចិត្តស្មើដោយភ្លើង ។

៥- កំចាត់ងងឹត គឺអវិជ្ជា បង្កើតពន្លឺ គឺបញ្ញាញាណ ។

## អង្គ ៥ របស់ខ្យល់

១- បក់ផាត់ក្លិនក្រអូបនៃផ្កាឈើទាំងឡាយឲ្យផ្សាយផ្សប់ទៅក្នុងដងព្រៃ ។

២- បក់ពោកព្រៃព្រឹក្សឲ្យបាក់ខ្ទេចខ្ទី និងជីកឫសរំលើងគល់រហូតដល់ឫសកែវ ។

៣- តែងបក់ផាត់ទៅក្នុងអាកាស ។

៤- ផ្សាយក្លិនអប់ផ្សប់ផ្សាយទៅ ។

៥- មិនមានកាលវេ មិនមានលំនៅ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការគឺ ៖

១- ត្រេកអរក្នុងនិព្វានារម្មណ៍ ដូចជនៅព្រៃផលមានផ្កាឈើរកនឹង ក្រគួបដឹងក្រលែងគឺវិមុត្តិ ។

២- ពិចារណាសង្ខារ ដូចខ្យល់ផែលបក់ទៅក្នុងជនៅព្រៃដើម្បី បំផ្លាញកិលេសទាំងឡាយ ។

៣- ញាំងចិត្តឲ្យត្រាច់ទៅក្នុងលោកុត្តរធម៌ទាំងឡាយ ។

៤- ហាត់ស្រូបកិនដង្ហើមឲ្យឈប់ឈប់ គឺសីលរបស់ខ្លួន ។

៥- មិនមានកាលវេ មិនមានលំនៅជាអ្នករួចរបួតផុតដេះស្រឡះ ។

## អង្គ ៥ របស់ភ្នំ

១- មិនរញ្ជួយ មិនកំរើក មិនញាប់ញ័រ ។

២- ជារបស់រឹងប៉ុន មិនប្រឡូកប្រឡំដោយគេគុនមួយឡើយ ។

៣- ដំណាំមិនដុះនៅលើកំពូលភ្នំនោះឡើយ ។

៤- ខ្ពស់ឡើងទៅជាលំដាប់ ។

៥- មិនងើកងោកទៅមក ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ ៖

១- មិនត្រេកអរ មិនអន់ចិត្តក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍

មិនស្រឡាញ់ មិនរីង មិនរង្វើង ក្នុងអារម្មណ៍ជាទីតាំង នៃសេចក្តីត្រេកអរ មិនរីងមិនរង្វើង មិនញាប់ញ័រ មិនរញ្ជួយដូចជាភ្នំ ។

២ – មិនច្របូកច្របល់ដោយសង្ខារ ដែលជាទីកកើតនៃកិលេសគ្រឿងសៅហ្មងចិត្ត ។

៣ – មិនបើកឱកាសបន្ទោះ ឲ្យកិលេសទាំងឡាយកើតឡើងក្នុងចិត្តរបស់ខ្លួន ។

៤ – ជាអ្នកប្រសើរវិសេសដោយប្រាជ្ញាញាណ ។

៥ – កាលបើមានឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ មកប៉ះពាល់ចិត្ត ក៏មិនមានសោមនស្សនិងទោមនស្សឡើយ ។

## អង្គ ៥ របស់អាកាស

១ – ទោះអ្នកណាទីមួយ គេនឹងចាប់រក្សាទុកមិនបានទាំងអស់ ។

២ – ជាទីត្រាច់ទៅនៃពួកឫសីតាបសនិងសត្វបក្សីទាំងឡាយ ។

៣ – មានផ្ទៃបន្ទារ ។

៤ – មិនមានទីបំផុត គណនាមិនបាន ប្រមាណមិនត្រូវ ។

៥ – មិនមានជាប់ជំពាក់ មិនមានទីតាំងមិនមានអាល័យ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ:

១ – មិនបើកឱកាសបន្ទោះឲ្យកិលេសទាំងឡាយ ចូលមកប្រតិដោយប្រការទាំងពួង ។

២ — ញ៉ាំងចិត្តឲ្យត្រេបទៅក្នុងសង្ខារទាំងឡាយ ដោយពិចារណាទៅតាមព្រះត្រៃលក្ខណ៍ ។

៣ — ភ័យសង្ស័យក្នុងការទៅកាន់បដិសន្ធិក្នុងភពទាំងពួង ព្រោះសេចក្តីសុខក្នុងភពមានទុក្ខជាផលផ្លែអាក្រក់ ។

៤ — មានសតិធំថាយ៉ាងដ៏បរិសុទ្ធរះញាណ ចិត្តមានបំផុតមានញាណដ៏ចាស់ក្លាប្រាជ្ញាណាមិនស្មាន ។

៥ — ជាអ្នកមិនជាប់ជំពាក់ ចិត្តមិនចាំទីតាំង មិនមានសេចក្តីអាល័យក្នុងបច្ច័យនិងកិលេសទាំងពួង ។

## អង្គ ៥ របស់ព្រះចន្ទ្រ

១ — ក្នុងសុក្កបក្ខរះពន្លឺឡើងថ្លាត្រចះត្រចង់ដ៏ក្រៃលែង ។

២ — ជាធំដ៏ក្រៃលែង ។

៣ — អណ្តែតត្រៃសត្វក្នុងវេលារាត្រី ។

៤ — មានវិមានជាទង់ជ័យ ។

៥ — មនុស្សលោកនាំគ្នាអង្វរសុំឲ្យរះពន្លឺនៅជានិច្ច ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ:

១ — ចំរើនឡើងៗក្នុងកុសលធម៌ទាំងពួង ។

២ — មានឆន្ទៈជាអធិបតីដ៏ឧឡារិក ។

៣- មានកាយវាចាចិត្ត ប្រកបដោយសេចក្ដីស្ងប់ត្រជាក់ ។

៤- មានសីលជាទង់ជ័យ ។

៥- កាលត្រកូលចូលមកសូមអារាធនានិមន្ត ក៏ចូលទៅកាន់ត្រកូលទាំងឡាយតាមសេចក្ដីត្រូវការប្រាថ្នារបស់គេ ។

## អង្គ ៥ របស់ដំរី

១- ត្រាច់ចូលទៅក្នុងព្រៃ តែងយកជើងឈូសវៃនដី ។

២- សំឡឹងមើលតែសព្វកាយខ្លួន មិនមើលមើលទៅកាន់ទិសផ្សេងៗឡើយ ។

៣- មិនដេកប្រចាំនៅទីណាមួយជានិច្ចឡើយ ចេញទៅស្វែងរកអាហារបាននៅទីណា ក៏ចូលទៅអាស្រ័យនៅទីនោះ មិនអាល័យទីលំនៅ ។

៤- ទីងចុះងូតទឹក ក៏ច្រើនតែចុះក្នុងស្រះឈូកដ៏ធំទូលាយ មានទឹកថ្លាស្អាត មិនកករល្អក់ ដ៏ដេរដាសទៅដោយមើមឈូក ទីងផ្កាឈូកជាច្រើន ហើយតែងចុះលេងទឹកតាមដំណើរដំរី ។

៥- ទីងលើកជើងក៏មានស្មារតី ទីងដាក់ជើងចុះក៏មានស្មារតី ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ:

១- ពិចារណាតែពង់កាយ ដើម្បីបំផ្លាញកិលេសទាំងឡាយ ។

២- ពិតពិលមើលតែសព្វកាយ មិនសំឡឹងមើលទៅទិសទាំងឡាយ

មិនងើយមើលលើ មិនឈ្ងោកមើលក្រោម ពោះភ្នែកក្រឡេកមើលទៅត្រឹមរយៈ ១ នឹមរទេះ ។

៣ - មិនមានលំនៅប្រចាំជានិច្ច មិនមានអាល័យត្រេចទៅទីណាជាទីភ្ជាប់ចិត្តនឹងសមគួរ គ៏ចូលទៅអាស្រ័យទីនោះ មិនជាប់ចិត្តអាឡោះអាល័យលំនៅ ។

៤ - ចំរើនមហាសតិបដ្ឋាន ដែលមានទំនងដូចជាស្រះបោក្ខរណី ( ស្រះឈូក ) ដ៏គេញាប្រៀបទៅដោយធម៌ដ៏ប្រសើរ ត្រជាក់មិនកករល្អក់ ថ្លាស្អាតប្រាសចាកមន្ទិល ដ៏ដេរដាសដោយមើមឈូកនឹងផ្កាឈូកគឺវិមុត្តិ ពិចារណាវិញកសង្ខារដោយញាណ ។

៥ - មានសតិសម្បជញ្ញៈនៅគ្រប់ឥរិយាបថ ។

# អង្គ ៥ របស់ព្រៃ

១ - មិនបាំងវុតចូលមនុស្សអិទស្អាត ។

២ — ជាទីចំនេរ អំតមនុស្សត្រេចទៅៈត្រចមក ។

៣ — ជាទីស្ងប់ស្ងាត់ ។

៤ — ជាទីស្ងប់ម្ងាប់ដ៏បរិសុទ្ធ ។

៥ — ជាទីដែលព្រះគរិយៈតាំងឡាយតែងៈសពគប់ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការគឺៈ

១ — បិទបាំង មិនបើកផ្សាយប្រកាសទោស សេចក្ដីភ្លាំងភ្លាត់ការសម្ងាត់របស់ជនដទៃ ។

២ — សាបសូន្យចាកកិលេសទាំងឡាយ មានរាគៈទោសៈមោហៈជាដើម ។

៣ — ស្ងប់ស្ងាត់ចាកអកុសលបាបធម៌ទាំងឡាយ ។

៤ — ជាអ្នកស្ងប់រម្ងាប់ដ៏បរិសុទ្ធ ។

៥ — ជាអ្នកគឺព្រះអរិយបុគ្គលគប្បីសេពគប់សមាគម ។

## អង្គ ៥ របស់មេឃ

១ — រម្ងាប់ផង់ហុយធូលីលើផែនដី ។

២ — រំលត់កំដៅនៅផែនដីឲ្យត្រជាក់ ។

៣ — ញ៉ាំងដំណាំគ្រប់យ៉ាងឲ្យដុះលូតលាស់ល្អ ។

៤ — ជាកំណើតនៃទឹក ហើយតែងធ្លាក់ចុះមកតាមរដូវកាលតែងរក្សាគុម្ពស្មៅ ដើមឈើ វល្លិជាដើមឲ្យដុះលូតលាស់ល្អ ។

៥ — បន្ទុះចុះមកកន្លែងទីផ្សេងៗមានស្ទឹងទន្លេ ស្រះបោក្ខរណី អណ្ដូងត្រពាំងបឹងបួជាដើម ញ៉ាំងទីទាំងនោះឲ្យពេញទៅដោយទឹក ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការគឺ :

១ — រម្ងាប់កិលេសដូចជាផង់ហុយធូលី ដែលកើតឡើង ឲ្យអស់ទៅទាល់តែផុតពូជ ។

២ — ចំរើនមេត្តាភាវនា ដែលអាចរម្ងាប់កំហឹងរបស់មនុស្សទាំងទេវតាទាំងឡាយ ធ្វើឲ្យត្រជាក់ក្សាន ។

៣ — ញុំាងសទ្ធា ដែលទុកដូចជាពូជរបស់សព្វសត្វឲ្យចំរើនលូតលាស់ល្អ ក្នុងសម្បត្តិទាំង ៣ គឺសម្បត្តិរបស់មនុស្ស សម្បត្តិរបស់ទេវតា និងសម្បត្តិ គឺព្រះនិព្វាន ។

៤ — ញុំាងយោនិសោមនសិការៈឲ្យកើតឡើងហើយរក្សាសមណធម៌ដោយយោនិសោមនសិការៈនោះ ព្រោះកុសលធម៌ទាំងពួង សុទ្ធមានយោនិសោមនសិការៈជាមូលហេតុ ។

៥ — ញុំាងភ្លៀង គឺបរិយត្តិ បដិបត្តិ បដិវេធ ឲ្យបង្អុរចុះមក ហើយញុំាងចិត្តរបស់អ្នកប្រាថ្នាបដិវេធឲ្យបានពេញលេញឡើង ។

---

ប្រវត្តិសង្ខេបរបស់ឧបាសក ហួត-ទិន

ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ

ឧបាសក ហួត-ទិន ជាបុត្រឧបាសកហួត និងឧបាសិកា នាង កើតនៅថ្ងៃ ៣ ៗ ៦ ឆ្នាំមមែ ក្នុងឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ ។ កាលពីកុមារបានសិក្សារៀនសូត្រអក្សរខ្មែរ និងបួសរៀននៅវត្តឆ្លូង បាន ៤ វស្សា លាចាកសិក្ខាបទក្នុងវ័យអាយុ ២០ ឆ្នាំ បានរួមសមរស និងនាងស្រីខៃ ជាបុត្រីលោកអ្នកឧកញ៉ាសៅ និងអ្នកស្រីថោង ។

កាលស្វាមីភរិយាគូនេះនៅរួមសុខទុក្ខជាមួយគ្នាទៅ ក៏បង្កើតបានកូនប្រុស-ស្រីដល់ ៨ នាក់ (ប្រុស ៤ ស្រី ៤) គួរពប់ថាជាគ្រួសារមានកូនស្តុកស្តម្ភមួយ ហើយបានរៀបចំឲ្យកូនទាំងនោះមានស្វាមី-ភរិយា តាមប្រពៃណីលោកទាំងអស់គ្នា ។ ឧបាសកហួត-ទិន និងឧបាសិកាខៃ ជាអ្នកមានសទ្ធាជ្រះថ្លាមាំមួន ក្នុងព្រះពុទ្ធសាសនា នៅឱកាសដែលកំពុងចំរើនដោយសម្បត្តិធនធាន បានធ្វើបុណ្យទានផ្សេងៗ ជាច្រើនយ៉ាង ដូចបុណ្យកឋិនទានជាដើម ។ លើកយកចំពោះការកុសលធំៗ ដែលឧបាសកហួត-ទិន បានសាងជាមួយនឹងគ្រួសារគឺ (១) សាងចេតិយ ១ ធ្វើដោយបេតុងការម៉េទំហំជើងកោស ៧ ម៉ែត្រកន្លះ កំពស់ ១៥ ម៉ែត្រ អស់ចំនួនធនធាន ៧,០០០រ ០០ សម្រាប់ជាទីបញ្ចុះអដ្ឋិធាតុរបស់មាតាបិតាបង្កើត និងមាតាបិតាក្មេកនៅក្នុងវត្តសិលានទីឆ្លូងក្រោ ។

(២) បានបុណ្យបច្ច័យជួយកសាងវិហារវត្តសិលានខាងនោះ ចំនួន ២.១០០៛០០ (៣) បានផាវព្រះត្រៃបិដកដែលពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយចំនួន ១ ចប់ ដ៏ថ្លៃ ៥៥០៛.០០ ។

ឧបាសក ហួត-ចិន បានប្រកបការកេស៊ីដោយសម្មាអាជីវៈ រួមរួមជាមួយនឹងគ្រួសារ ជាសុខសប្បាយរហូតដល់អាយុ ៦០ មានពេក-ពាធកាន់តែច្រើនឡើងជានិច្ច ទើបពិចារណាយល់ឃើញជាមរណភ័យកាន់តែខ្លាំងចូលមកជិតជីវិតគាត់ហើយ ។ បណ្ដាកូនចៅប្រុស-ស្រីក៏នាំគ្នាមកជួបជុំពុំហានដើរចោលឆ្ងាយ ហើយបាននិមន្តព្រះសង្ឃមកសូត្រស្វាធ្យាយជាប់រាល់ ។ យប់ ដរាបដល់ថ្ងៃសៅរ៍ ខាំមមែបញ្ចស័ក ត្រូវនឹងថ្ងៃ ១៨ ស៊ូយេត ឆ្នាំ ១៩៥៤ វេលាម៉ោង ១១ ឧបាសកហួត-ចិន ក៏អនិច្ចកម្មទៅដោយស្រួល នៅចំពោះមុខកូនប្រុស-ស្រីនិងញាតិមិត្តជិតខាងសឹងគគ្រប់យ៉ាងនៅជួបជុំគ្រប់គ្រា ។ ក្នុងខណៈនោះ គេបានឮសូរ យំសោកស្រណោះអាឡោះអាល័យនៃបុត្របុត្រានិងញាតិមិត្តលាន់ឮពេញរំពង គួរឲ្យអាណោចអាធ័មណាស់ បន្ទាប់ពីនោះ ពួកយោគីក៏ចាត់ចែងធ្វើកិច្ចសព្វគ្រប់តាមរបៀបប្រពៃណី ។

លុះដល់ថ្ងៃពុធ ១២ កើតខែអាសាឍ ជាថ្ងៃគំរប់ ៥ ពេលម៉ោង ១០ ព្រឹក ពួកកូនចៅ ទាំងប្រុសទាំងស្រី ព្រមទាំងពួកញាតិមិត្តទាំងចិន ទាំងខ្មែរ

បានមកជួបជុំព្រមមុខគ្នា ពួកសាហាវ្យយោគីកិលេសព ពុះបាក់គេ-ហស្ថានជវផ្ទៃទៅមានក្រុងចិន ក្រុងខ្មែរជាច្រើនដែរ ប្រកិច្ចស្លូវធំគួរឲ្យស្រងេះស្រងោចពន់ពេកដកបះទៅដល់វត្តលិលានទី (ត្បូងក្រៅ) ហើយនិមន្តព្រះសង្ឃបំសុកូល រួចកិលេសបញ្ចុះទៅក្នុងចេតិយ នៅវត្តនោះឯង ។

* *
*

ឱអនិច្ចាសង្ខារសព្វសត្វ កើតឡើងហើយតែងខ្លាត់ព្រាត់ព្រាសគ្នាជាធម្មតា ព្រះពុទ្ធដីកាបានសំដែងទុកថា សត្វលោកទាំងអស់ តែងមានជាតិ (កំណើត) ជាខាងដើម មានជរាព្យាធិ (ចាស់, ឈឺ) នៅកណ្ដាល មានមរណៈ (សេចក្ដីស្លាប់) នៅទីបំផុត ហើយជីវិតសត្វលោកតែងជាប់ជំពាក់នៅក្នុងវង្វង់ព្រះត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា ជាដរាប មិនអាចគេចវេះចៀសវាងឲ្យផុតទៅបានឡើយ ។